**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: **០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក**
ភាគីដាក់ឯកសារ មេធាវីការពារក្តី លោកស្រី អៀង ធីរិទ្ធ
ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ **សាធារណៈ**/Public
ចំណាត់ថ្នាក់ប្រភេទឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Oct-2012, 10:02
CMS/CFO: Ly Bunloung

---

**ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងបណ្តឹងសាទុក្ខផ្សេងៗរបស់សហព្រះរាជអាជ្ញាជំទាស់នឹង សេចក្តីសម្រេចលើលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ តុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ និងសារណាបន្ថែមរបស់សហព្រះរាជអាជ្ញា**

---

**ដាក់ដោយ:** **អង្គជំនុំជម្រះតុលាការកំពូល:**

**សហមេធាវី:** **ចៅក្រម គង់ ស្រ៊ឹម ជាប្រធាន**
ផាត់ ពៅស៊ាង **ចៅក្រម** Florence Ndepele Mwachande MUMBA
Diana ELLIS, QC

ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Agnieszka KLONOWIECKA-MILART
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម យ៉ា ណារិន

**សហមេធាវីនាំមុខតំណាងម្ចាស់បណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**សហព្រះរាជអាជ្ញា៖**
ជា លាង
Andrew CAYLEY

## I. សេចក្តីផ្តើម និង បណ្តឹង

1. នៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញ "សេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១" ("សេចក្តីសម្រេចដែលរងការជំទាស់")[1]។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើសេចក្តីសន្និដ្ឋានជាឯកច្ឆ័ន្ទថា លោកស្រី អៀង ធីរិទ្ធ ("ចុងបណ្តឹងសាទុក្ខ") បានទទួលរងនូវស្ថានភាពជំងឺវង្វេងស្មារតីដែលចេះតែវិវឌ្ឍន៍ទៅមុខ (ទំនងយ៉ាងខ្លាំងថាជាជំងឺ Alzheimer)[2] និងបានបញ្ជាក់សាជាថ្មីថា គាត់ពុំមានសម្បទាក្នុងការចូលរួមសវនាការ បន្តការផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងរូបគាត់នៅក្នុងសំណុំរឿង ០០២ ដោយគ្មានពេលកំណត់ និងបង្គាប់ឲ្យដោះលែងគាត់ជាបន្ទាន់ចេញពីមន្ទីរឃុំឃាំង អ.វ.ត.ក[3]។

2. នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញា ("ម្ចាស់បណ្តឹងសាទុក្ខ") បានដាក់ "បណ្តឹងសាទុក្ខភ្លាមៗជំទាស់ទៅនឹងសេចក្តីសម្រេចលើការវាយតម្លៃឡើងវិញ អំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១" ("បណ្តឹងសាទុក្ខ")[4] ដែលស្នើសុំឲ្យផ្អាកការដោះលែងចុងបណ្តឹងសាទុក្ខសិន[5]។ ម្ចាស់បណ្តឹងសាទុក្ខបានស្នើថា សេចក្តីសម្រេចដែលរងការជំទាស់គួរត្រូវទុកជាមោឃៈ ដោយសារអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ខ្លួនពុំមាន

---

[1] សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១, ឯកសារលេខ E138/1/10, ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ ("សេចក្តីសម្រេចដែលរងការជំទាស់")។

[2] *ដូចខាងលើ,* កថាខណ្ឌ ២៤។

[3] *ដូចខាងលើ,* កថាខណ្ឌ ១៩។

[4] បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ជំទាស់ទៅនឹងសេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១", ឯកសារលេខ E138/1/10/1/1, ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ("បណ្តឹងសាទុក្ខរបស់ ក.ស.ព")។

[5] សំណើរបស់សហព្រះរាជអាជ្ញា សុំផ្អាកការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, ឯកសារលេខ E138/1/10/1/2, ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២។

យុត្តាធិការដើម្បីសម្រេចទៅលើការត្រួតពិនិត្យតាមផ្លូវតុលាការមានលក្ខខណ្ឌ ដែលមានមូលដ្ឋានគតិយុត្តិ និងកែប្រែសេចក្តីសម្រេចដើម្បីតម្រូវឱ្យចុងបណ្តឹងសាទុក្ខ (ប្រសិនបើចាំបាច់តាមរយៈអាណាព្យាបាលទូទៅ) ដើម្បីឱ្យអនុវត្តលក្ខខណ្ឌជាក់លាក់ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា ដើម្បីការពារឱ្យបានសមស្របទៅនឹងសិទ្ធិ និងផលប្រយោជន៍តាមផ្លូវច្បាប់ដែលទាក់ទងទៅនឹងការដោះលែងជនជាប់ចោទចេញពីមន្ទីរឃុំឃាំង[6]។

3. នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ បន្ទាប់ពីព្រះរាជអាជ្ញានៃការិយាល័យអយ្យការអមសាលាដំបូងរាជធានីភ្នំពេញបានដាក់សំណើមួយ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ ("ព្រះរាជអាជ្ញា") រួចមកសាលាដំបូងរាជធានីភ្នំពេញបានចេញសេចក្តីសម្រេចមួយ ដោយជ្រើសតាំងលោកស្រី អៀង វីជីដា ជាអាណាព្យាបាលទូទៅសម្រាប់ចុងបណ្តឹងសាទុក្ខ ("ដីកាសម្រេចជ្រើសតាំងអាណាព្យាបាល")[7]។

4. នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១២ ប្រធានអង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បានបង្គាប់ឱ្យដោះលែងចុងបណ្តឹងសាទុក្ខ ចំណែកឯលក្ខខណ្ឌនានាត្រូវរង់ចាំការសម្រេចលើបណ្តឹងសាទុក្ខសិន[8]។

5. នៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២ អ.ជ.ត.ក បានចេញ "សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់សារណាបន្ថែមលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចដោះលែង អៀង ធីរិទ្ធ"[9] ដោយបានពិចារណាឃើញថា បណ្តឹងសាទុក្ខស្ថិតក្រោមរបបនីតិវិធីដែលមានចែងក្នុងវិធាន ១០៧(២) និង ១០៨(៤)(ស្ទួន)(ក) នៃវិធានផ្ទៃក្នុង[10]។

6. នៅថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១២ ម្ចាស់បណ្តឹងសាទុក្ខបានដាក់ "បណ្តឹងសាទុក្ខភ្លាមៗជំទាស់ទៅនឹងសេចក្តីសម្រេចលើការវាយតម្លៃឡើងវិញ អំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការ

---

[6] បណ្តឹងសាទុក្ខរបស់ ក.ស.ព, កថាខណ្ឌ ១៩។

[7] ដីកាសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ, ឯកសារលេខ E138/1/10/1/2/3.1, ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២។

[8] ដីកាសម្រេចរបស់ប្រធាន អ.ជ.ត.ក លើសំណើរបស់សហព្រះរាជអាជ្ញា សុំផ្អាកសេចក្តីសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, ឯកសារលេខ E138/1/10/1/2/1, ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១២, ទំព័រ ៣៤ (ភាសាអង់គ្លេស)។

[9] សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់សារណាបន្ថែមលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចដោះលែង អៀង ធីរិទ្ធ, ឯកសារលេខ E138/1/10/1/3/1, ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២។

[10] *ដូចខាងលើ*, ទំព័រ ៣ (ភាសាអង់គ្លេស)។

កំពូលចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ សារណាបន្ថែមរបស់សហព្រះរាជអាជ្ញា" ("សារណាបន្ថែម")[11]។

7. សម្រាប់សំអាងហេតុដូចខាងក្រោម ចុងបណ្តឹងសាទុក្ខសូមលើកឡើងថា៖

១) អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសលើអង្គច្បាប់ទេក្នុងការសន្និដ្ឋានថា ខ្លួនពុំមានយុត្តាធិការទៅលើចុងបណ្តឹងសាទុក្ខ ដើម្បីបង្គាប់ឱ្យត្រួតពិនិត្យតាមផ្លូវច្បាប់ចំពោះលក្ខខណ្ឌដោយបង្ខំ ពុំមានកំហុសលើអង្គច្បាប់ទេក្នុងការខកខានមិនបានពិចារណាទៅលើមូលដ្ឋានគតិយុត្តិ ដែលមានសម្រាប់បន្តការត្រួតពិនិត្យតាមផ្លូវតុលាការដោយមានលក្ខខណ្ឌ និងជាងនេះទៀត ពុំមានកំហុសលើអង្គច្បាប់ទេដោយបង្គាប់ឱ្យដោះលែងចុងបណ្តឹងសាទុក្ខដោយគ្មានលក្ខខណ្ឌបង្ខំនោះ។

២) អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសលើអង្គហេតុ ឬលើការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការសន្និដ្ឋានថា លក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការមិនអាចយកមកប្រើ ឬអនុវត្តបាននោះ។

## II. ប្រវត្តិទាក់ទងនឹងការសន្និដ្ឋានពីភាពពុំមានសម្បទាក្នុងការចូលរួមសវនាការ

8. ចុងបណ្តឹងសាទុក្ខសូមយោងទៅដល់ខ្លឹមសារនៃកថាខណ្ឌ ៤-១០ នៃ "ចម្លើយតបរបស់មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១"[12] ដែលមានរៀបរាប់ដោយសង្ខេបនូវប្រវត្តិផ្នែកវេជ្ជសាស្ត្រដែលនាំឱ្យអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា ចុងបណ្តឹងសាទុក្ខពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ នៅឆ្នាំ ២០១១ បាន។

9. បន្ទាប់ពីមានបណ្តឹងសាទុក្ខពីម្ចាស់បណ្តឹងសាទុក្ខ[13] ជំទាស់នឹង "សេចក្តីសម្រេចលើសម្បទារបស់របស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ"[14] របស់អង្គជំនុំជម្រះសាលាដំបូងមក នៅថ្ងៃទី ១៣

[11] សារណាបន្ថែមរបស់សហព្រះរាជអាជ្ញា, ឯកសារលេខ No. E138/1/10/1/5, ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១២។

[12] ចម្លើយតបរបស់មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E138/1/5, ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[13] បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, ឯកសារលេខ E138/1/1, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១។

ខែ ធ្នូ ឆ្នាំ ២០១១ អ.ជ.ត.ក បានបង្គាប់អង្គជំនុំជម្រះសាលាដំបូងឲ្យមានការព្យាបាលបន្ថែមទៀតសម្រាប់ចុងបណ្តឹងសាទុក្ខ ដែលអាចនឹងធ្វើឲ្យសុខភាពផ្លូវចិត្តរបស់គាត់បានប្រសើរឡើង ដើម្បីឲ្យមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ[15]។ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំតុលាការឲ្យចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ និងលោកសាស្ត្រាចារ្យ Campbell ("អ្នកជំនាញវេជ្ជសាស្ត្រ") ដើម្បីចាប់ផ្តើមការព្យាបាលផ្នែកវេជ្ជសាស្ត្រនេះ[16]។

10. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ អ្នកជំនាញវេជ្ជសាស្ត្របានដាក់ "របាយការណ៍ទាក់ទងនឹងលោកស្រី អៀង ធីរិទ្ធ តាមសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០១២"[17]។ អ្នកជំនាញវេជ្ជសាស្ត្របានទទួលស្គាល់ថា ឱសថកែរោគចិត្តទាំងអស់ដែលចុងបណ្តឹងសាទុក្ខបានប្រើប្រាស់ត្រូវបានកាត់បន្ថយ និងបញ្ឈប់ និងថា "មុខងារបញ្ញាស្មារតីរបស់ជនជាប់ចោទពុំមានភាពប្រសើរជាងមុនឡើយ"[18]។ ឱសថ Donepezil ត្រូវបានចាប់ផ្តើមប្រើប្រាស់នៅថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ រហូតដល់ថ្ងៃទី ១១ ខែ វិច្ឆិកា ហើយដោយសារតែមានផលប៉ះពាល់នោះ ចុងបណ្តឹងសាទុក្ខត្រូវសម្រាកនៅមន្ទីរពេទ្យ[19]។ អ្នកជំនាញវេជ្ជសាស្ត្របានសន្និដ្ឋានថា ចុងបណ្តឹងសាទុក្ខ "មានការខូចខាតប្រព័ន្ធប្រសាទក្នុងកម្រិតពីមធ្យមទៅធ្ងន់ធ្ងរ ដែលឈានទៅដល់ជំងឺបាត់បង់សមត្ថភាពផ្នែកបញ្ញាស្មារតី ហើយដែលទំនងបំផុតអាចជាជំងឺ Alzheimer ហើយក៏

---

[14] សេចក្តីសម្រេចរបស់ អ.ជ.ស.ដ លើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ, ឯកសារលេខ E138, ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើកទីមួយរបស់ អ.ជ.ស.ដ លើសម្បទាក្នុងការចូលរួមសវនាការ")។

[15] សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, ឯកសារលេខ E138/1/7, ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១, ទំព័រ ២៤ (ភាសាអង់គ្លេស) ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក")។

[16] អនុស្សរណៈរបស់ អ.ជ.ស.ដ ដែលមានចំណងជើងថា "សំណើទៅអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខជំទាស់នឹងការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ (E138/1/7)", ឯកសារលេខ E138/1/7/1, ចុះថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០១២, កថាខណ្ឌ ៣-៤។

[17] របាយការណ៍ទាក់ទងនឹងលោកស្រី អៀង ធីរិទ្ធ ដាក់ជូនតាមសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០១២, ឯកសារលេខ E138/1/7/4, ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២។

[18] *ដូចខាងលើ,* កថាខណ្ឌ ៧។

[19] ដូចគ្នា។

អាចពាក់ព័ន្ធនឹងសរសៃឈាមទៀតផង"[20]។ ពួកគេបានកត់សម្គាល់ពីការវិវឌ្ឍន៍នៃជំងឺបាត់បង់សមត្ថភាពផ្នែកបញ្ញាស្មារតីរបស់គាត់ដែល "មានសភាពយ៉ាប់យ៉ឺនជាងកាលពីពេលវាយតម្លៃមុនៗ"[21]។ អ្នកជំនាញវេជ្ជសាស្ត្របានផ្តល់អនុសាសន៍ឲ្យកាត់បន្ថយការប្រើប្រាស់ថ្នាំ benzodiazepine និងឈានទៅដល់ការបញ្ឈប់តែម្តង ដោយណែនាំឲ្យប្រើប្រាស់បន្ទះបិតព្យាបាល Rivastigmine ប្រចាំថ្ងៃវិញ និងគួរបង្កើតឲ្យមានកម្មវិធីជំរុញបញ្ញាស្មារតីដែលមានការរៀបចំត្រឹមត្រូវ តែបានកត់សម្គាល់ថា "អនុសាសន៍ទាំងនេះក៏ទំនងជាគ្មានសង្ឃឹម [...] ធ្វើឲ្យស្ថានភាពជនជាប់ចោទល្អប្រសើរគ្រប់គ្រាន់ សម្រាប់ចូលរួមក្នុងការការពារខ្លួនឯងឡើយ"[22]។

11. បន្ទាប់ពីការប្រើប្រាស់បន្ទះបិតព្យាបាល Rivastigmine អស់រយៈពេលជាង ២០ សប្តាហ៍ និងអនុវត្តកម្មវិធីជំរុញបញ្ញាស្មារតីដែលមានការរៀបចំត្រឹមត្រូវអស់រយៈពេល ៣ ខែមក ចុងបណ្តឹងសាទុក្ខត្រូវបានវាយតម្លៃឡើងវិញ នៅថ្ងៃទី ២៧ និង ២៨ ខែ សីហា ឆ្នាំ ២០១២។ អ្នកជំនាញវេជ្ជសាស្ត្របានសន្និដ្ឋានជាឯកច្ឆ័ន្ទនៅក្នុង "របាយការណ៍សង្ខេបរបស់អ្នកជំនាញពាក់ព័ន្ធនឹងលោកស្រី អៀង ធីរិទ្ធ" របស់ខ្លួន បន្ទាប់ពីបានបញ្ចាក់នៅក្នុងសវនាការលើសម្បទាថ្ងៃទី ៣០-៣១ ខែ សីហា ឆ្នាំ ២០១២ ថា គាត់មានជំងឺវង្វេងស្មារតីក្នុងកម្រិតពីមធ្យមទៅធ្ងន់ធ្ងរ[23]។ ពួកគេបានអះអាងថា ពុំមានភស្តុតាងណាមួយបង្ហាញពីការធូរស្រាលទេ បន្ទាប់ពីការប្រើប្រាស់បន្ទះបិតព្យាបាល Rivastigmine និងកម្មវិធីជំរុញបញ្ញាស្មារតី ហើយពេលវេលាគ្រប់គ្រាន់ ដើម្បីឲ្យការព្យាបាលទាំងនេះទទួលបានប្រសិទ្ធភាពបានកន្លងទៅហើយ ប្រសិនបើការព្យាបាលទាំងនេះនឹងមានប្រសិទ្ធភាពនោះ[24]។ ផ្ទុយទៅវិញ អ្នកជំនាញវេជ្ជសាស្ត្របានកត់សម្គាល់ពីស្ថានភាពចុះដុនដាបនៃសមត្ថភាពបញ្ញាស្មារតីរបស់ចុងបណ្តឹងសាទុក្ខចាប់តាំងឆ្នាំ ២០១១ មក ពាក់ព័ន្ធនឹងការចងចាំ បានទទួលពិន្ទុទាបក្នុងការធ្វើតេស្តវាយតម្លៃផ្លូវចិត្ត រោគសញ្ញាផ្នែកអាកប្បកិរិយា និងសមត្ថភាពក្នុង

---

[20] ដូចគ្នា។

[21] ដូចគ្នា។

[22] *ដូចខាងលើ,* កថាខណ្ឌ ៨។

[23] របាយការណ៍សង្ខេបរបស់អ្នកជំនាញពាក់ព័ន្ធនឹងលោកស្រី អៀង ធីរិទ្ធ, ឯកសារលេខ E138/1/7/13/2, ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២, កថាខណ្ឌ ៦០ ("របាយការណ៍សង្ខេបរបស់អ្នកជំនាញ")។

[24] *ដូចខាងលើ,* កថាខណ្ឌ ៥៨។

ការយកចិត្តទុកដាក់ចំពោះខ្លួនគាត់ និងមុខងារប្រចាំថ្ងៃមានការថយចុះ[25]។ អ្នកជំនាញវេជ្ជសាស្ត្របានសន្និដ្ឋានថា ចុងបណ្ដឹងសាទុក្ខនៅតែមិនអាចជួយក្នុងការរៀបចំការការពារខ្លួន និងមានការលំបាកពាក់ព័ន្ធទៅនឹងសម្បទាក្នុងការឆ្លើយតបទៅនឹងបទចោទ និងការចូលរួមសវនាការ[26]។ ពួកគេបានកត់សម្គាល់ថា ពួកគេពុំមានវិធីព្យាបាលណាផ្សេងទៀតទេ ហើយថា បច្ចុប្បន្ននេះពុំមានការព្យាបាលបន្ថែមទៀត ដើម្បីឲ្យសមត្ថភាពបញ្ញាស្មារតីរបស់ចុងបណ្ដឹងសាទុក្ខបានប្រសើរឡើង[27]។ អ្នកជំនាញវេជ្ជសាស្ត្របានអះអាងជាឯកច្ឆ័ន្ទថា ពុំមានលទ្ធភាពថា ជំងឺវង្វេងស្មារតីនេះនឹងបានប្រសើរឡើយ ហើយថា ពួកគេមិនបានដឹងពីភាពប្រសើរឡើងវិញនៃអ្នកជំងឺវង្វេងស្មារតី ដោយដកចេញនូវមូលហេតុផ្សេងទៀតទាំងអស់[28]។ ពួកគេបានបញ្ជាក់ថា ជំងឺវង្វេងស្មារតីជាជំងឺដែលវិវត្តទៅមុខ ហេតុនេះស្ថានភាពរបស់ចុងបណ្ដឹងសាទុក្ខគឺបន្តកាន់តែដុនដាបទៅៗ[29]។ ជំងឺនេះពាក់ព័ន្ធនឹងការបំផ្លាញកោសិកាខួរក្បាលដែលមិនអាចលូតលាស់ជាថ្មីបាន[30]។

12. ភាគីទាំងអស់ លើកលែងតែដើមបណ្ដឹងរដ្ឋប្បវេណី បានលើកឡើងថា ចុងបណ្ដឹងសាទុក្ខពុំមានសម្បទាក្នុងការចូលរួមសវនាការទេ ហើយគួរតែដោះលែងចេញពីមន្ទីរឃុំឃាំង[31]។ មេធាវីការពារក្ដីបានស្នើសុំថា ចុងបណ្ដឹងសាទុក្ខគួរតែត្រូវបានដោះលែងដោយគ្មានលក្ខខណ្ឌ[32]។ សហព្រះរាជអាជ្ញាបានលើកឡើងថា គាត់គួរត្រូវបានដោះលែងក្រោមរបបនៃការត្រួតពិនិត្យតាមផ្លូវតុលាការដោយមានលក្ខខណ្ឌចំនួន ៦ គឺ៖

---

[25] *ដូចខាងលើ,* កថាខណ្ឌ ៦១។ សូមមើល ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១២, ឯកសារលេខ E1/118.1, ទំព័រ ២២ (ភាសាអង់គ្លេស); ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២, ឯកសារលេខ E1/119.1, ទំព័រ ២២, ២៩-៣០ (ភាសាអង់គ្លេស)។

[26] របាយការណ៍សង្ខេបរបស់អ្នកជំនាញ, កថាខណ្ឌ ៦២។

[27] *ដូចខាងលើ,* កថាខណ្ឌ ៥៩; ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១២, ទំព័រ ២២ (ភាសាអង់គ្លេស); ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២, ទំព័រ ៣១ (ភាសាអង់គ្លេស)។

[28] ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២, ទំព័រ ៧៥ (ភាសាអង់គ្លេស)។

[29] *ដូចខាងលើ,* ទំព័រ ២៩-៣០, ៥១-៥២, ៩៦ (ភាសាអង់គ្លេស)។

[30] *ដូចខាងលើ,* ទំព័រ ៩៦ (ភាសាអង់គ្លេស)។

[31] *ដូចខាងលើ,* ទំព័រ ១០២-១០៣, ១២៩ (ភាសាអង់គ្លេស)។

[32] *ដូចខាងលើ,* ទំព័រ ១២៩, ១៣៣-១៣៧ (ភាសាអង់គ្លេស)។

(១) បង្គាប់ឱ្យគាត់ស្នាក់នៅក្នុងអាសយដ្ឋានមួយជាក់លាក់ ដែលសហមេធាវីរបស់គាត់ត្រូវផ្ដល់ព័ត៌មានមកតុលាការ។

(២) គាត់គប្បីមានវត្តមានដើម្បីឱ្យពិនិត្យពីសុវត្ថិភាពរបស់គាត់ ប្រចាំសប្ដាហ៍ដោយអាជ្ញាធរ ឬក៏មន្ត្រីណាមួយដែលចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង។

(៣) បង្គាប់ឱ្យគាត់ប្រគល់ជូនលិខិតឆ្លងដែន និងអត្តសញ្ញាណបណ្ណរបស់គាត់មកតុលាការ។

(៤) បង្គាប់មិនឱ្យគាត់ទាក់ទងដោយផ្ទាល់ ឬដោយប្រយោលជាមួយជនជាប់ចោទផ្សេងទៀត (ដោយមិនរាប់បញ្ចូលស្វាមីគាត់ អៀង សារី ទេ)។

(៥) បង្គាប់មិនឱ្យគាត់ទាក់ទងដោយផ្ទាល់ ឬដោយប្រយោលជាមួយសាក្សី អ្នកជំនាញ ឬជនរងគ្រោះដែលអង្គជំនុំជម្រះសាលាដំបូងនឹងកោះអញ្ជើញមកផ្ដល់សក្ខីកម្ម និងមិនត្រូវជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះឡើយ។ និង

(៦) បង្គាប់ឱ្យគាត់ទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រយ៉ាងទៀងទាត់រៀងរាល់ ៦ ខែម្ដងដោយគ្រូពេទ្យជំនាញ ដែលចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង[33]។

13. នៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចដែលរងការជំទាស់ ដោយបានបញ្ជាក់សាជាថ្មីថា ចុងបណ្ដឹងសាទុក្ខពុំមានសម្បទាក្នុងការចូលរួមសវនាការទេ ហើយថា ពុំមានការរំពឹងសមហេតុផលដែលថា ការធ្លាក់ចុះខ្សោយខាងបញ្ញាស្មារតីរបស់គាត់អាចត្រូវបានធ្វើឱ្យប្រសើរឡើងវិញបានឡើយ ដោយសារ "ការខិតខំប្រឹងប្រែងប្រើប្រាស់គ្រប់វិធានការទាំងអស់ដើម្បីធ្វើឱ្យប្រសើរឡើងនូវមុខងារខាងបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ ត្រូវបានធ្វើអស់លទ្ធភាពហើយ" ហើយ ទោះបីជាមានការប្រើប្រាស់គ្រប់វិធានការហើយក្ដី ក៏គាត់នៅតែពុំអាចមានសមត្ថភាពក្នុងការអនុវត្តសិទ្ធិជាមូលដ្ឋាន ក្នុងការទទួលបានការជំនុំជម្រះដោយអត្តន័យឡើយ[34]។ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យដោះលែងចុងបណ្ដឹងសាទុក្ខភ្លាម ដោយសារខ្លួនពិចារណាឃើញថា ខ្លួនពុំមានមូលដ្ឋានគតិយុត្តិក្នុងការធ្វើយុត្តិកម្មបន្តការឃុំខ្លួនគាត់ក្នុងកាលៈទេសៈបច្ចុប្បន្ននេះទេ ពោលគឺពុំអាចមានសវនាការណាមួយចំពោះរូបគាត់ក្នុងពេលអនាគត

---

[33] *ដូចខាងលើ,* ទំព័រ ១០៩-១១០។

[34] សេចក្ដីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ២៤។

ដ៏ខ្លីដែលអាចប្រមើលដឹងទេ[35]។ សម្រាប់សំអាងហេតុដូចគ្នានេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ខ្លួនពុំមានមូលដ្ឋានគតិយុត្តិច្បាស់លាស់ដើម្បីកំណត់លក្ខខណ្ឌដោយបង្ខំ ឬដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមទម្រង់ផ្សេងៗទៀតលើចុងបណ្តឹងសាទុក្ខ នៅពេលដោះលែងទេ[36]។ ក្នុងករណីណាក៏ដោយ ដោយពិចារណាទៅលើស្ថានភាពសុខភាពរបស់គាត់នាពេលនេះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការកំណត់លក្ខខណ្ឌទៅលើចុងបណ្តឹងសាទុក្ខមិនអាចអនុវត្តបានតាមសភាពជាក់ស្តែង ឬតាមផ្លូវច្បាប់ទេ[37]។ ចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់សាជាថ្មីពីការសន្និដ្ឋានរបស់ខ្លួនថា ចុងបណ្តឹងសាទុក្ខពុំមានសម្បទាក្នុងការចូលរួមសវនាការ បន្តការផ្អាកកិច្ចដំណើរការនីតិវិធីពីមុនដោយគ្មានពេលកំណត់ និងបង្គាប់ឲ្យដោះលែងគាត់ជាបន្ទាន់ចេញពីមន្ទីរឃុំឃាំង អ.វ.ត.ក[38]។

## III. បទប្បញ្ញត្តិច្បាប់

### ៣.១ ច្បាប់នៅ អ.វ.ត.ក និងច្បាប់កម្ពុជា

14. វិធាន ៦៥(១) នៃវិធានផ្ទៃក្នុងចែងថា សហចៅក្រមស៊ើបអង្កេតអាចចេញបង្គាប់ឲ្យដោះលែងជនត្រូវចោទពីមន្ទីរឃុំឃាំងបានដោយដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងអាចកំណត់លក្ខខណ្ឌមួយចំនួនជាការ “ចាំបាច់ ដើម្បីធានាអំពីវត្តមានរបស់ជនត្រូវចោទក្នុងកិច្ចដំណើរការនីតិវិធី និងដើម្បីការពារក្តីអ្នកដទៃទៀត”។ វិធាន ៦៥(៦) នៃវិធានផ្ទៃក្នុងចែងថា៖ “បើជនត្រូវចោទរំលោភលក្ខខណ្ឌដែលមានចែងក្នុងដីកានេះ សហចៅក្រមស៊ើបអង្កេតអាចចេញសេចក្តីព្រមាន ឬចេញដីកាឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទនោះបាន”។

15. វិធាន ៨២(១) នៃវិធានផ្ទៃក្នុងចែងថា ជនជាប់ចោទត្រូវមានសេរីភាពរហូតដល់ពេលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង លើកលែងតែមានការបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ។ វិធាន ៨២(២) នៃវិធានផ្ទៃក្នុងចែងបន្ថែមថា៖ “គ្រប់ពេលនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះអាចបង្គាប់ឲ្យដោះលែងជនជាប់ចោទ ឬដាក់ឲ្យស្ថិតក្រោមការ

---

[35] *ដូចខាងលើ,* កថាខណ្ឌ ២៦-៣០។

[36] *ដូចខាងលើ,* កថាខណ្ឌ ៣៣។

[37] *ដូចខាងលើ,* កថាខណ្ឌ ៣៧។

[38] *ដូចខាងលើ,* ទំព័រ ១៩ (ភាសាអង់គ្លេស)។

ត្រួតពិនិត្យតាមផ្លូវតុលាការក្នុងករណីចាំបាច់ ឬ បង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទបាន ស្របតាមវិធានផ្ទៃក្នុងនេះ”។

16. វិធាន ១០៤(១) នៃវិធានផ្ទៃក្នុងចែងថា អ.ជ.ត.ក ត្រូវសម្រេចលើបណ្តឹងសាទុក្ខ ជំទាស់ទៅនឹងសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

    ក) កំហុសលើអង្គច្បាប់ ដែលនាំឲ្យមោឃៈសាលក្រមលើអង្គសេចក្តី ឬ សេចក្តីសម្រេចនោះ។ ឬ

    ខ) កំហុសលើអង្គហេតុដែលនាំឲ្យសាលក្រមលើអង្គសេចក្តី ឬ សេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។

បន្ថែមពីនេះ បណ្តឹងសាទុក្ខភ្លាមៗអាចធ្វើទៅបានដោយផ្អែកលើមូលដ្ឋាននៃ “ការភ័ន្តច្រឡំ ដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ”។ វិធាន ១០៤(៤) នៃវិធានផ្ទៃក្នុងចែងថា សេចក្តីដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី និងសេចក្តីសម្រេចអំពីការឃុំខ្លួន និងការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការអនុលោមតាមវិធាន ៨២ អាចប្តឹងសាទុក្ខភ្លាមៗបាន។

17. បើតាមវិធាន ១០៥(២) នៃវិធានផ្ទៃក្នុង ភាគីដាក់ពាក្យបណ្តឹងសាទុក្ខភ្លាមៗត្រូវបញ្ជាក់ពីមូលដ្ឋានគាំទ្រនីមួយៗ ដូចជា៖

    ក) បញ្ជាក់អំពីកំហុសលើអង្គច្បាប់ និងត្រូវបង្ហាញថា កំហុសនោះបណ្តាលឲ្យសេចក្តីសម្រេចមានមោឃៈ។ ឬ

    ខ) បញ្ជាក់អំពីកំហុស ដែលស្តែងឡើងពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។ ឬ

    គ) បញ្ជាក់អំពីកំហុសលើអង្គហេតុ និងត្រូវបង្ហាញថា កំហុសនេះនាំឲ្យមានការភ័ន្តច្រឡំក្នុងការសម្រេចសេចក្តីរបស់តុលាការ។

18. មាត្រា ១៣ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ចែងថា សិទ្ធិរបស់ជនជាប់ចោទដែលមានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) រួមមានសិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ និងសិទ្ធិទទួលការសន្មតជាមុនថាគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់ “ត្រូវតែគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី”។

19. អនុលោមតាមមាត្រា ២៤ នៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក គឺថា រាជរដ្ឋាភិបាលកម្ពុជា មានការទទួលខុសត្រូវក្នុងការ "ចាត់វិធានសមស្រប និងមានប្រសិទ្ធភាព ដែលចាំបាច់ដើម្បីធានា សន្តិសុខ សុវត្ថិភាព និងការការពារចំពោះបុគ្គលដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ" និងធានា សន្តិសុខរបស់ជនជាប់ចោទដែរ។

20. មាត្រា ៣៣ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ចែងថា " [...] ប្រសិនបើនីតិវិធីដែលមានស្រាប់ ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយឬអនុវត្ត នីតិវិធីនោះ [...] គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលមានបង្កើតឡើងក្នុងកម្រិត អន្តរជាតិ"។

21. មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (CCCP) អនុញ្ញាតឲ្យចៅក្រមស៊ើបសួរអាចដាក់ ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ប្រសិនបើ "ជនត្រូវ ចោទនេះ ត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ"។ មាត្រា ២៣០ នៃ CCCP ចែងថា "ប្រសិនបើជនត្រូវចោទគេចវេះដោយចេតនាពីកាតព្វកិច្ចតាមផ្លូវតុលាការ ចៅ ក្រមស៊ើបសួរអាចសម្រេចឲ្យឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នបាន"។

22. អនុលោមតាមមាត្រា ២៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា (CCKC) តុលាការអាច ប្រកាសពីការចាប់ផ្ដើមភាពជាអាណាព្យាបាលទូទៅសម្រាប់បុគ្គលណាម្នាក់ "ដែលនៅក្នុង ស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃ សកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី"។ មាត្រា ១០២៨ នៃ CCKC ចែងថា អាណាព្យាបាលទូទៅត្រូវចាត់តែងទ្រព្យសម្បត្តិរបស់ជន ដែលស្ថិតក្រោមអាណាព្យាបាលទូទៅ និងមាត្រា ១០៣៩(១) ចែងអំពីអ្នកគ្រប់គ្រងអាណាព្យាបាលទូទៅ ឬ តុលាការអាច "អង្កេតពី ស្ថានភាពរស់នៅ និងការថែទាំសុខភាពរបស់ជន ដែលស្ថិតក្រោមអាណាព្យាបាលទូទៅ និងការ ចាត់តែងទ្រព្យសម្បត្តិ"។ មាត្រា ១០៤៣ ចែងពីកាតព្វកិច្ចរបស់អាណាព្យាបាលទូទៅ ដើម្បី បំពេញភារកិច្ចរបស់ខ្លួនដោយមានការយកចិត្តទុកដាក់ពីអ្នកចាត់ចែងល្អម្នាក់។

## ៣.២ ច្បាប់អន្តរជាតិ

23. មាត្រា ៩(១) នៃ ICCPR បានចែងពីសិទ្ធិជាមូលដ្ឋាននៃការមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន រួម មានសិទ្ធិមិនត្រូវចាប់ខ្លួន ឬ ឃុំខ្លួនតាមអំពើចិត្តឡើយ។ មាត្រានេះក៏បានចែងបន្ថែមទៀតថា "គ្មាន

ជនណាម្នាក់ត្រូវបានដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់"។ មាត្រា ៩(៣) ចែងពីសិទ្ធិទទួលបានការជំនុំជម្រះក្តីក្នុងពេលសមស្រប ឬត្រូវដោះលែង។ មាត្រានេះចែងបន្ថែមទៀតថា "ការឃុំខ្លួនមនុស្សដើម្បីរង់ចាំការជំនុំជម្រះគឺមិនមែនជាវិធានទូទៅទេ ប៉ុន្តែការឱ្យនៅក្រៅឃុំត្រូវតែមានការធានាការចូលខ្លួនរបស់ជននោះ នៅពេលសវនាការ ឬនៅគ្រប់ដំណាក់កាលដទៃទៀតនៃនីតិវិធី"។ ស្រដៀងគ្នានេះដែរ មាត្រា ៥ នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្សនៅទ្វីបអឺរ៉ុប (ECHR) ចែងពីការការពារសិទ្ធិមានសេរីភាព។

24. មាត្រា ១៤(២) នៃ ICCPR ចែងថា៖ "ជនគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌមានសិទ្ធិទទួលការសន្មតជាមុនថាគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់"។

## IV. **សេចក្តីសន្និដ្ឋាន**

25. មេធាវីការពារក្តីសូមលើកឡើងថា ពុំមានមូលដ្ឋានណាមួយយកមកសំអាងដើម្បីមោឃៈ ឬ កែប្រែសេចក្តីសម្រេចដែលរងការជំទាស់នោះទេ។

### ៤.១ **អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសលើអង្គច្បាប់ដោយសារការផ្អាកយុត្តាធិការរបស់ខ្លួនលើចុងបណ្តឹងសាទុក្ខទេ**

26. ម្ចាស់បណ្តឹងសាទុក្ខលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ក្នុងការសម្រេចថា ខ្លួនពុំមានមូលដ្ឋានគតិយុត្តិដើម្បីកំណត់លក្ខខណ្ឌដោយបង្ខំ ឬដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតាមទម្រង់ផ្សេងៗទៀតលើចុងបណ្តឹងសាទុក្ខ បន្ទាប់ពីដោះលែងភ្លាម ដោយផ្អែកលើការសន្និដ្ឋានដែលថា យុត្តាធិការរបស់ខ្លួនត្រូវបានផ្អាក ហើយថាខ្លួនមិនអាចអនុវត្តយុត្តាធិការរបស់ខ្លួនទៅលើ "ជនជាប់ចោទដែលទំនងជាមិនអាចយកមកជំនុំជម្រះវិញបាន ហើយត្រូវបានដោះលែង" ទេ[39]។

27. មុនពេលដោះស្រាយចំពោះមូលដ្ឋាននេះនៃបណ្តឹងសាទុក្ខនោះ ជាការចាំបាច់ដែលត្រូវវិភាគទៅលើកាលៈទេសៈនានាដែលនាំឱ្យអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា យុត្តាធិការរបស់ខ្លួនទៅលើចុង

---

[39] បណ្តឹងសាទុក្ខរបស់ ក.ស.ព, កថាខណ្ឌ ៥-៦ ដោយយោងទៅលើសេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ៣៣។

បណ្តឹងសាទុក្ខត្រូវបានផ្អាកនោះ។ នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា តាមប្រព័ន្ធច្បាប់ជាតិ និងតាមច្បាប់យុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអឺរ៉ុបគឺថា "ការបន្តឃុំខ្លួនជនជាប់ចោទដែលពុំមានសម្បទាខាងបញ្ញាស្មារតីដើម្បីចូលរួមសវនាការអាចមានយុត្តិកម្ម លុះត្រាតែមានលទ្ធភាពខ្ពស់ដែលថា ជនជាប់ចោទអាចប្រែជាមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ ដើម្បីចូលរួមសវនាការនាពេលខាងមុខដែលគេអាចប្រមើលដឹង"[40]។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ចុងបណ្តឹងសាទុក្ខ "ពុំទំនងជាធូរស្រាលតាមរយៈការព្យាបាលបន្ថែមឡើយ" និងថា "ពុំមានលទ្ធផលសមហេតុផលថា ភាពទន់ខ្សោយផ្នែកបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ អាចនឹងបានធូរស្រាលទេ"[41]។ អង្គជំនុំជម្រះបានអះអាងបន្ថែមថា "សេចក្តីសម្រេចផ្អាកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានចេញកាលពីពេលមុនត្រូវបន្តដោយគ្មានពេលកំណត់"[42]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "ការឃុំខ្លួនលោកស្រី អៀង ធីរិទ្ធ ជាបណ្តោះអាសន្ន [...] ប្រសិនបើបន្តឃុំខ្លួនតទៅទៀត ដោយមិនប្រាកដថា នឹងមានការជំនុំជម្រះលើរូបគាត់នៅពេលណាមួយនោះ" នឹងរំលោភសិទ្ធិជាមូលដ្ឋាននានារបស់គាត់[43]។ ជំហរនេះត្រូវបានម្ចាស់បណ្តឹងសាទុក្ខគាំទ្រ នៅពេលខ្លួនទទួលស្គាល់ថា ចុងបណ្តឹងសាទុក្ខទំនងជាពុំអាចចូលរួមក្នុងសវនាការ នាពេលខាងមុខដែលអាចប្រមើលដឹងបានទេ[44]។ ជាងនេះទៀត ម្ចាស់បណ្តឹងសាទុក្ខបានទទួលស្គាល់ដោយមានសរសេរជាលាយលក្ខណ៍អក្សរក្នុងបណ្តឹងសាទុក្ខរបស់ខ្លួនដែលខ្លួនអះអាងថា សេចក្តីសម្រេចដែលរងការជំទាស់ស្របតាមបទប្បញ្ញត្តិនៃវិធាន ១០៤(៤)(ក) ជាសេចក្តីសម្រេចដែលមានមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី[45]។

28. នៅក្នុងបណ្តឹងសាទុក្ខ ដំបូងម្ចាស់បណ្តឹងសាទុក្ខលើកឡើងជាទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ដោយសំអាងថា សេចក្តីសម្រេចដែលរងការជំទាស់ងាកចេញពី

---

[40] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ២៣; សូមមើលផងដែរ កថាខណ្ឌ ២១-២២។

[41] *ដូចខាងលើ*, កថាខណ្ឌ ២៥។

[42] *ដូចខាងលើ*, កថាខណ្ឌ ២៨។

[43] *ដូចខាងលើ*, កថាខណ្ឌ ៣១។

[44] ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២, ទំព័រ ១០៣ (ភាសាអង់គ្លេស)។

[45] បណ្តឹងសាទុក្ខរបស់ ក.ស.ព, កថាខណ្ឌ ៥។

ច្បាប់នៅ អ.វ.ត.ក និងគោលការណ៍ជាមូលដ្ឋាននៃច្បាប់កម្ពុជា ដោយមិនបានផ្តល់នូវមូលដ្ឋានគតិយុត្តិសម្រាប់តុលាការមួយ ដើម្បីដកខ្លួនចេញពីយុត្តាធិការដោយស្ម័គ្រចិត្ត ក្នុងករណីដែលបណ្តឹងអាជ្ញាមួយមិនត្រូវបានបញ្ចប់ដោយច្បាប់[46]។ ម្ចាស់បណ្តឹងសាទុក្ខយោងទៅដល់មាត្រា ៧ និង ៨ នៃ CCCP រួមទាំងសេចក្តីសម្រេចរបស់ អ.ជ.ត.ក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១។

29. ចុងបណ្តឹងសាទុក្ខអះអាងថា ការបកស្រាយសេចក្តីសម្រេចដែលរងការជំទាស់បែបនេះបង្ហាញពីវិធីសាស្ត្រជាទម្រង់ និងកំហុសមិនសមរម្យនៃការបង្ហាញសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាដំបូងមិនបានដកហូតនូវយុត្តាធិការរបស់ខ្លួនទេ តែបានទទួលស្គាល់យ៉ាងត្រឹមត្រូវពីដែនកំណត់ដែលអាចមានលើការអនុវត្តយុត្តាធិការផ្នែកព្រហ្មទណ្ឌនោះ ពាក់ព័ន្ធនឹងកាលៈទេសគតិយុត្តិ និងការអនុវត្តជាក់ស្តែងនៃសេចក្តីសម្រេចរបស់ខ្លួនក្នុងការផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងចុងបណ្តឹងសាទុក្ខ ដោយគ្មានពេលកំណត់[47]។ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញពីការយល់យ៉ាងច្បាស់នូវលក្ខណៈនៃនីតិវិធីនៃការផ្អាកកិច្ចដំណើរការនីតិវិធី ដោយផ្តល់ការទទួលស្គាល់យ៉ាងពេញលេញ និងទម្ងន់ចំពោះកាលៈទេសៈនៃរឿងក្តីនេះ ភាពអចិន្ត្រៃយ៍នៃស្ថានភាពសុខភាពរបស់ចុងបណ្តឹងសាទុក្ខ និងភាពមិនអាចចៀសវាងបាននៃការចុះដុនដាបថែមទៀតនៃលទ្ធភាពផ្នែកបញ្ញាស្មារតីរបស់គាត់ ទៅតាមទស្សនៈយ៉ាងច្បាស់របស់អ្នកជំនាញវេជ្ជសាស្ត្រ[48]។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចយ៉ាងត្រឹមត្រូវក្នុងការផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងរូបគាត់ដោយគ្មានពេលកំណត់។

30. ម្ចាស់បណ្តឹងសាទុក្ខបានប្រកាន់ជំហរស្រដៀងគ្នានេះដែរ នៅពេលពួកគេលើកឡើងជាទឡ្ហីករណ៍ថា ការផ្អាកកិច្ចដំណើរការនីតិវិធីដែលបង្គាប់ដោយអង្គជំនុំជម្រះសាលាដំបូងនៅខែ វិច្ឆិកា ឆ្នាំ ២០១១ នោះនាំឲ្យមានការបញ្ចប់យ៉ាងមានប្រសិទ្ធភាព នូវកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងចុង

---

[46] បណ្តឹងសាទុក្ខរបស់ ក.ស.ព, កថាខណ្ឌ ៦ និង ៦(ក)។

[47] សូមមើល សេចក្តីសម្រេចរបស់ អ.ជ.ត.ក, កថាខណ្ឌ ២៤៖ "ប៉ុន្តែ ទោះបីជានៅក្នុងកាលៈទេសៈបែបនោះក្តី "តុលាការមិនចាំបាច់ហាមឃាត់មិនឲ្យ *អនុវត្តយុត្តាធិការជាអចិន្ត្រៃយ៍*ដែលពាក់ព័ន្ធនឹងបុគ្គលនោះទេ" ពីព្រោះចរិតនៃការផ្អាកកិច្ចដំណើរការនីតិវិធីដែលបង្គាប់ដោយអង្គជំនុំជម្រះសាលាដំបូង គឺមានលក្ខខណ្ឌ និងអាចបដិសេធចោលបាន" (គូសបញ្ជាក់បន្ថែមដោយយើងខ្ញុំ) ដោយយោងទៅដល់ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo*, សំណុំរឿងលេខ ICC-01/04-01/06 OA 12, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ដែលមានចំណងជើងថា "សេចក្តីសម្រេចដោះលែង Thomas Lubanga Dyilo", ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៨, កថាខណ្ឌ ៣៧។

[48] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ២៦-៣១។

បណ្តឹងសាទុក្ខ[49] ដែលបន្ទាប់មកក៏ត្រូវបានបញ្ជាក់ដោយ អ.ជ.ត.ក ដែរ[50]។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អ.ជ.ត.ក បានពិនិត្យឡើងវិញទៅលើយុត្តិសាស្ត្ររបស់តុលាការជាតិ និងអន្តរជាតិលើបញ្ហានេះ និងបានកំណត់ឃើញមានបម្រែបម្រួលពីរយ៉ាងនៃការផ្អាកកិច្ចដំណើរការនីតិវិធីគឺ៖ ការផ្អាកជាបណ្តោះអាសន្ននិងអាចប្រែប្រួល ដែលអនុញ្ញាតឲ្យមានដំណោះស្រាយមួយ និងការផ្អាកជាអចិន្ត្រៃយ៍និងមិនអាចត្រឡប់ក្រោយបានបានដែលជនជាប់ចោទត្រូវបានសន្និដ្ឋានថាពុំមានសម្បទាក្នុងការចូលរួមសវនាការទេ[51]។ ទាក់ទិននឹងភាពខុសគ្នានេះហើយដែលនាំឲ្យការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងថា ខ្លួនពុំមានសមត្ថភាពអនុវត្តយុត្តាធិការនោះត្រូវតែយកមកវាយតម្លៃ។

31. យោងទៅដល់កាលៈទេសៈនានាដូចបានលើកឡើងខាងលើនេះ ចុងបណ្តឹងសាទុក្ខសូមលើកឡើងថា មាត្រា ៧ និង ៨ នៃ CCCP ពុំពាក់ព័ន្ធនឹងករណីនេះទេ ដោយសារតែបទប្បញ្ញត្តិទាំងនេះផ្តើយតបតែទៅនឹងមូលហេតុដែលនាំឲ្យបញ្ចប់ការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌតែប៉ុណ្ណោះ ចំណែកឯអង្គជំនុំជម្រះសាលាដំបូងវិញគឺផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងចុងបណ្តឹងសាទុក្ខ ដោយគ្មានពេលកំណត់ទេ។ គេគួរកត់សម្គាល់ថា មាត្រា ៧ និង ៨ មិនបានផ្តល់លទ្ធភាពដល់ការផ្អាកជាអចិន្ត្រៃយ៍ទេ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ជាពាក្យពេចន៍ដូច្នេះថា “បទចោទប្រឆាំងនឹងជនជាប់ចោទនៅតែមាន ហើយសេចក្តីសម្រេចនេះពុំមែនសម្រេចអំពីអត្ថិភាព ឬនត្ថិភាពនៃពិរុទ្ធភាពរបស់ជនជាប់ចោទឡើយ”[52]។ សម្រាប់សំអាងហេតុដដែលនេះ ការណ៍ដែលម្ចាស់បណ្តឹងសាទុក្ខយោងទៅដល់ភាពខុសគ្នារវាងការផ្អាកកិច្ចដំណើរការនីតិវិធី និងការបញ្ចប់កិច្ចដំណើរការនីតិវិធីទាំងនោះដែលសម្រេចដោយ អ.ជ.ត.ក ពុំពាក់ព័ន្ធទេ។

32. ទីពីរ ម្ចាស់បណ្តឹងសាទុក្ខបានលើកជាទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តយ៉ាងខុសឆ្គងទៅលើសេចក្តីសន្និដ្ឋាននៃសាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ពាក់ព័ន្ធនឹងភាពមិនអាចធ្វើបានចំពោះការឃុំខ្លួនក្នុងករណីនៃ “ការផ្អាកដំណើរការ

---

[49] បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, កថាខណ្ឌ ៣-៦។

[50] សេចក្តីសម្រេចរបស់ អ.ជ.ត.ក, កថាខណ្ឌ ១៥។

[51] *ដូចខាងលើ,* កថាខណ្ឌ ១៦-៣១។

[52] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ៤០។

នីតិវិធីដែលមានមិនអាចត្រឡប់ក្រោយបាន និងជាអចិន្ត្រៃយ៍” ដើម្បីកុំឲ្យមានការអនុវត្តនូវវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការលើជនជាប់ចោទ អៀង ធីរិទ្ធ”[53]។ ម្ចាស់បណ្តឹងសាទុក្ខក៏បានអះអាងបន្ថែមទៀតថា ការសន្និដ្ឋានលើអង្គហេតុដែលថា ចុងបណ្តឹងសាទុក្ខពុំមានសម្បទាដើម្បីចូលរួមសវនាការជាអចិន្ត្រៃយ៍ជាលក្ខខណ្ឌតម្រូវមុនពេល មិនឲ្យមានការអនុវត្តការត្រួតពិនិត្យតាមផ្លូវតុលាការដោយមានលក្ខខណ្ឌ ហើយថា “អង្គជំនុំជម្រះសាលាដំបូងបានដាក់ការផ្អាកដែលអាចត្រឡប់ក្រោយបាន និងមិនមែនជាអចិន្ត្រៃយ៍ តាមរយៈការទទួលយកលទ្ធផលនៃការធ្វើឲ្យប្រសើរឡើងវិញតាមការព្យាបាលខាងវេជ្ជសាស្ត្រ ដែលមានលក្ខណៈប្រសើរជាងមុន”[54]។

33. ចុងបណ្តឹងសាទុក្ខ លើកឡើងថាទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ មិនភាពត្រឹមត្រូវទេ។ ទីមួយ អង្គជំនុំជម្រះសាលាដំបូង បានពិនិត្យមើលអំពីលទ្ធភាពជាក់ស្តែងនៃភាពធូរស្រាល ឬការជាសះស្បើយរួចហើយ និងបានសម្រេចថាមិនមានលទ្ធភាពបែបនោះទេ[55]។ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តតាមសេចក្តីណែនាំពីមុនរបស់អង្គជំនុំជម្រះតុលាការកំពូល ដោយបានខិតខំប្រើប្រាស់គ្រប់វិធានការទាំងអស់ ដើម្បីឲ្យចុងបណ្តឹងសាទុក្ខមានសភាពធូរស្រាលឡើងវិញ។ គាត់មិនមានភាពធូរស្រាលបន្ទាប់ពីទទួលបានការព្យាបាលទេ ប៉ុន្តែគាត់កាន់តែមានសភាពដុនដាបជាងមុន។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា ខ្លួនបានខិតខំប្រើប្រាស់វិធីព្យាបាលទាំងអស់ហើយ និងយល់ឃើញថាយោងតាមមតិយោបល់ជាឯកច្ឆន្ទរបស់អ្នកជំនាញវេជ្ជសាស្ត្រ ចុងបណ្តឹងសាទុក្ខ ពិតជាពុំមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ជាអចិន្ត្រៃយ៍ក្នុងការចូលរួមសវនាការ។ អង្គជំនុំជម្រះសាលាដំបូង ពុំមានភស្តុតាងណាមួយធ្វើជាសំអាងដើម្បីធ្វើសេចក្តីសន្និដ្ឋានផ្ទុយពីនេះឡើយ។ វាគ្រាន់តែប្រមើលមើលតែប៉ុណ្ណោះ ដោយមិនមានមូលដ្ឋានវេជ្ជសាស្ត្រ ក្នុងការសន្និដ្ឋានថាចុងបណ្តឹងសាទុក្ខ អាចធូរស្រាលនៅពេលណាមួយនោះ។ ដូចការយល់ឃើញរបស់អង្គជំនុំជម្រះបើសិនតាមលទ្ធភាពជាក់ស្តែង គាត់មិនអាចធូរស្រាលបានទេនោះ មិនមានមូលដ្ឋានផ្លូវច្បាប់សមស្របសម្រាប់ការឃុំឃាំង និង/ឬការត្រួតពិនិត្យតាមផ្លូវតុលាការ និងលក្ខខណ្ឌដោយបង្ខំ ដើម្បីធានាវត្តមានរបស់ជនជាប់ចោទ និងការមិនជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះឡើយ។ ការដាក់លក្ខខណ្ឌក្នុងស្ថានភាពបែបនេះ អាចត្រូវបានពិពណ៌នាថាស្ថិតនៅក្រៅយុត្តាធិការ

---

[53] បណ្តឹងសាទុក្ខរបស់ ក.ស.ព, កថាខណ្ឌ ៦(ខ) ដោយយោងទៅលើសេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៩។

[54] ដូចគ្នា។

[55] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៤, ២១ និង២៩។

របស់អង្គជំនុំជម្រះសាលាដំបូង។ ដើម្បីអនុវត្តយុត្តាធិការរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបាន ដាក់លក្ខខណ្ឌដើម្បីធានាវត្តមានរបស់ជនជាប់ចោទ និងការពារសុវត្ថិភាពរបស់សាធារណជន។ លក្ខខណ្ឌទាំងនេះ មិនមានភាពជាប់ទាក់ទងនឹងស្ថានភាពជាក់លាក់របស់ចុងបណ្តឹងសាទុក្ខឡើយ។

34. ផ្ទុយពីអំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ឆន្ទៈរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការពិគ្រោះជាមួយអ្នកជំនាញវេជ្ជសាស្ត្រៀងរាល់ឆ្នាំ ដើម្បីសាកសួរអំពីលទ្ធភាពនៃការរកឃើញការព្យាបាលជំងឺ Alzheimer មិនអាចចាត់ទុកថាជា "ការទទួលយកលទ្ធភាពនៃការធ្វើឲ្យប្រសើរឡើងវិញតាមការព្យាបាលខាងវេជ្ជសាស្ត្រដែលមានលក្ខណៈប្រសើរជាងមុនទេ"[56]។ តាមការពិត សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ច្បាស់ហើយថា សេចក្តីសន្និដ្ឋាននេះត្រូវបានធ្វើឡើងតាមអង្គហេតុដែលចុងបណ្តឹងសាទុក្ខ នឹងមិនមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ឡើងវិញក្នុងការចូលរួមសវនាការឡើយ។ នៅពេលលើកឡើងអំពីការផ្អាកកិច្ចដំណើរការនីតិវិធីដោយមិនកំណត់រយៈពេលអង្គជំនុំជម្រះសាលាដំបូង មិនបានបញ្ជាក់ពីផ្សេងទៀតឡើយ ក្រៅពីពន្យល់ពីទិដ្ឋភាពច្បាប់ជាក់លាក់សម្រាប់ការផ្អាកកិច្ចដំណើរនីតិវិធី[57]។ ក្នុងករណីរឿងក្តីនេះ ការលើកឡើងនេះ មិនប៉ះពាល់សេចក្តីសន្និដ្ឋានផ្សេងៗទៀតរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ ពោលគឺការមិនមានលទ្ធភាពមានបញ្ញាស្មារតីគ្រប់គ្រាន់ឡើងវិញ ដើម្បីឲ្យចុងបណ្តឹងសាទុក្ខចូលរួមក្នុងសវនាការបាន និងការដោះលែងចុងបណ្តឹងសាទុក្ខ ជាកាតព្វកិច្ច និងត្រូវឡើងភ្លាមៗដោយឥតលក្ខខណ្ឌ។ អង្គជំនុំជម្រះសាលាដំបូង សម្រេចដោយត្រឹមត្រូវថា ខ្លួនមិនមានសិទ្ធិអំណាចបញ្ចប់កិច្ចដំណើរការនីតិវិធីឡើយ[58]។

35. ទីបី ចុងបណ្តឹងសាទុក្ខ សន្និដ្ឋានថាអង្គជំនុំជម្រះសាលាដំបូង មិនមានកំហុសអង្គច្បាប់ក្នុងការអនុវត្តលក្ខណវិនិច្ឆ័យក្នុងរឿងក្តី *Lubanga* ទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តតាមលក្ខណវិនិច្ឆ័យក្នុងរឿងក្តី *Lubanga* ដោយយកចិត្តទុកដាក់។ បន្ទាប់ពីធ្វើការវាយតម្លៃលើភាពមិនមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ជាអចិន្ត្រៃយ៍ក្នុងការចូលរួមក្នុងសវនាការ[59] អង្គជំនុំ

[56] បណ្តឹងសាទុក្ខភ្លាមៗរបស់ក.ស.ព កថាខណ្ឌ ៦ (ខ)។

[57] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៨។

[58] សូមមើលផងដែរ សេចក្តីសម្រេចទីមួយរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសម្បទាខាងបញ្ញាស្មារតី កថាខណ្ឌ ៦១ និង៦៤ និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ១៨។

[59] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២៦-៣១។

ជម្រះសាលាដំបូង ធ្វើសេចក្តីសន្និដ្ឋានដោយត្រឹមត្រូវថាការឃុំខ្លួនបន្ត នឹងរំលោភសិទ្ធិជាសារវន្ត របស់ចុងបណ្តឹងសាទុក្ខ[60]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង បានធ្វើការថ្លឹងថ្លែងសំណើ របស់ម្ចាស់បណ្តឹងសាទុក្ខសុំភ្ជាប់លក្ខខណ្ឌនៃការដោះលែងចុងបណ្តឹងសាទុក្ខ និងសន្និដ្ឋានថា មិនមានមូលដ្ឋានច្បាប់សម្រាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងដាក់លក្ខខណ្ឌទាំងនោះឡើយ[61]។

36. ជាចុងក្រោយ ម្ចាស់បណ្តឹងសាទុក្ខ យល់ឃើញថាសេចក្តីសម្រេចដែលរងការជំទាស់មានកំហុស អង្គច្បាប់ ដោយបានដាក់ម្ចាស់បណ្តឹងសាទុក្ខ ក្នុងស្ថានភាពដែលមិនអាចទទួលបានអំពីភាពមិន ប្រាកដប្រជាខាងផ្លូវច្បាប់ ដោយសារអង្គជំនុំជម្រះសាលាដំបូងបានផ្អាកយុត្តាធិការរបស់ខ្លួនលើ ជនជាប់ចោទ ដោយពុំមានការត្រួតពិនិត្យណាមួយតាមលក្ខខណ្ឌតម្រូវនៃច្បាប់សិទ្ធិមនុស្សអន្តរ ជាតិឡើយ[62]។ ដូចបានលើកឡើងហើយ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ច្បាស់អំពី ផលវិបាកផ្លូវច្បាប់ និងផលវិបាកជាក់ស្តែងនានាក្នុងការវាយតម្លៃរបស់ខ្លួនថាចុងបណ្តឹងសាទុក្ខ មិនមាន ហើយនឹងមិនមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមក្នុងសវនាការឡើយ ពោលគឺត្រូវផ្អាកកិច្ចដំណើរការនីតិវិធី ដោយមិនកំណត់រយៈពេល និងដោះលែងចុងបណ្តឹង សាទុកភ្លាមៗ ដោយគ្មានលក្ខខណ្ឌ។ អាស្រ័យហេតុនេះ ចុងបណ្តឹងសាទុក មិនស្ថិតក្នុងស្ថានភាព មិនប្រាកដប្រជា ដែលមិនអាចទទួលយកបានឡើយ។

37. លើសពីនេះ ម្ចាស់បណ្តឹងសាទុក្ខ ខកខានមិនបានបង្ហាញថាតើម្ចាស់បណ្តឹងសាទុក្ខស្ថិតនៅក្រៅ ការការពាររបស់តុលាការយ៉ាងដូចម្តេច ឬបញ្ជាក់ពីវិសាលភាព និងដើមហេតុនៃការការពារដែល បានលើកឡើងនោះទេ។ មាត្រា២៤ នៃកិច្ចព្រមព្រៀង អ.វ.ត.ក ដាក់បន្ទុកឲ្យរាជរដ្ឋាភិបាលកម្ពុជា ទទួលខុសត្រូវ និងតម្រូវឲ្យរាជរដ្ឋាភិបាលកម្ពុជាធានានូវសន្តិសុខ សុវត្ថិភាព និងការការពារ ជនជាប់ចោទ។ ចុងបណ្តឹងសាទុក្ខ នៅតែជាជនជាប់ចោទនៅចំពោះមុខ អ.វ.ត.ក [63]។

38. ចុងបណ្តឹងសាទុក្ខ ជំទាស់ទៅនឹងការលើកឡើងរបស់ម្ចាស់បណ្តឹងសាទុក្ខថាច្បាប់សិទ្ធិមនុស្ស អន្តរជាតិ តម្រូវឲ្យពិនិត្យមើល*ស្ថានភាពបច្ចុប្បន្ន* ក្រោយពេលចេញសេចក្តីសម្រេចដែលរង ការជំទាស់។ កាតព្វកិច្ច ពិនិត្យមើលឡើងវិញ មានទំនាក់ទំនងមិនអាចកាត់ផ្តាច់បានពីសិទ្ធិមាន

---

[60] *ដូចខាងលើដែរ*, កថាខណ្ឌ ៣១។

[61] *ដូចខាងលើដែរ*, កថាខណ្ឌ ៣២-៣៤។

[62] បណ្តឹងសាទុក្ខភ្លាមៗរបស់ក.ស.ព កថាខណ្ឌ ៦ (គ)។

[63] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៤០។

សេរីភាព ក្នុងអំឡុងកិច្ចដំណើរនីតិវិធីនៃការជំនុំជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយគ្មានការពន្យារពេលដោយមិនសមស្រប ជាស្ថានភាពដែលចុងបណ្តឹងសាទុក្ខ ទទួលរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ[64] និងនៅពេលមានលទ្ធភាពជាក់ស្តែងនៃការធ្វើឲ្យមានភាពប្រសើរ ឬការប្រែប្រួល[65]។ ម្ចាស់បណ្តឹងសាទុក្ខបានទទួលស្គាល់ចំណុចនេះ នៅពេលខ្លួនអះអាងថាការពិនិត្យសុខភាពជាទៀងទាត់ដែលបានស្នើឡើងអាចនឹង "ធានាថាអៀង ធីរិទ្ធ មិនត្រូវប្រឈមមុខនឹងពេលវេលាមិនកំណត់នៃការដាក់កំហិតលើសេរីភាពរបស់គាត់ឡើយ"[66]។

39. ផ្ទុយទៅវិញ ចុងបណ្តឹងសាទុក្ខ សន្និដ្ឋានថាសំណើរបស់ម្ចាស់បណ្តឹងសាទុក្ខដើម្បីដាក់លក្ខខណ្ឌដោយបង្ខំលើការដោះលែងរូបគាត់ អាចនឹងបង្កើតឲ្យមានភាពមិនប្រាកដប្រជាផ្លូវច្បាប់ទៅ វិញទេ។ ម្ចាស់បណ្តឹងសាទុក្ខទទួលស្គាល់ថាចុងបណ្តឹងសាទុក្ខ មានភាពចុះខ្សោយបញ្ញាស្មារតីកម្រិតពីមធ្យមទៅធ្ងន់ធ្ងរ ហើយគាត់មានសភាពកាន់តែដុនដាបជាងមុន។ វាមិនអាចយល់បានឡើយ ដែលម្ចាស់បណ្តឹងសាទុក្ខលើកឡើងថានៅពេលនេះការដាក់លក្ខខណ្ឌដោយបង្ខំ មានហេតុផលសមស្រប ប៉ុន្តែតម្រូវឲ្យមានការពិនិត្យមើលយ៉ាងទៀងទាត់ដើម្បីជៀសវាង "ការដាក់កំហិតដែលមិនកំណត់រយៈពេល ទាក់ទងនឹងសិទ្ធិមានសេរីភាពរបស់គាត់"។ លើសពីនេះ មិនមានហេតុផលសមស្របឡើយ ដែលម្ចាស់បណ្តឹងសាទុក្ខលើកឡើងថាការដាក់លក្ខខណ្ឌឲ្យចុងបណ្តឹងសាទុក្ខស្នាក់ នៅអាសយដ្ឋានណាមួយច្បាស់លាស់[67] ផ្តល់ភាពប្រាកដប្រជាជាង ដើម្បីឲ្យគាត់បន្តស្ថានភាពជាជនជាប់ចោទ។ ចុងបណ្តឹងសាទុក សន្និដ្ឋានថាមិនកំហុសអង្គច្បាប់ដែលតម្រូវឲ្យធ្វើមោឃៈភាពផ្នែកខ្លះនៃសេចក្តីសម្រេចដែលរងការជំទាស់ឡើយ។

## ៤.២ *អង្គជំនុំជម្រះសាលាដំបូង មិនមានកំហុសអង្គច្បាប់តាមរយៈការមិនអនុវត្ត ការច្រានចោល ឬការខកខានក្នុងការពិចារណាពីមូលដ្ឋានច្បាប់ដែលមានស្រាប់សម្រាប់ការបន្តការត្រួតពិនិត្យតាមផ្លូវតុលាការលើជនជាប់ចោទ ដោយមានលក្ខខណ្ឌឡើយ*

[64] *សូមមើល* រឿងក្តី *Antoine* តទល់នឹងការអនុវត្តរបស់ចក្រភពអង់គ្លេស លេខ 62960/00, ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៣។

[65] *សូមមើល រឿងក្តី* Lubanga *ដកស្រង់* កថាខណ្ឌ ៣៧។

[66] ប្រតិចារិក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ១១០ (ភាសាអង់គ្លេស)។

[67] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ក.ស.ព កថាខណ្ឌ ២២។

40. ម្ចាស់បណ្ដឹងសាទុក្ខលើកឡើងថាអង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់តាមរយៈការមិនអនុវត្ត ការច្រានចោល ឬការខកខានក្នុងការពិចារណាពីមូលដ្ឋានច្បាប់ដែលមានស្រាប់សម្រាប់ការបន្តការត្រួតពិនិត្យតាមផ្លូវតុលាការលើជនជាប់ចោទ ដោយមានលក្ខខណ្ឌ ដោយអនុលោមតាមមាត្រា២២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃកម្ពុជា និងវិធាន ៦៣, ៦៥ និង៨២ នៃវិធានផ្ទៃក្នុង[68]។

41. ទីមួយ ម្ចាស់បណ្ដឹងសាទុក្ខលើកឡើងថា មាត្រា ២២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃកម្ពុជា ចែងអំពីមូលដ្ឋានច្បាប់សម្រាប់ការដាក់វិធានការដោយបង្ខំ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណា ឬអនុវត្តបទប្បញ្ញត្តិនេះក្នុងករណីនៃរឿងក្ដីនេះ[69]។ ទោះជាយ៉ាងនេះក្ដី អង្គជំនុំជម្រះសាលាដំបូងបានពិចារណាអនុវត្តបទប្បញ្ញត្តិនេះ ក្នុងសេចក្ដីសម្រេចដែលរងការជំទាស់របស់ខ្លួន ដូចមតិភាគច្រើនរបស់ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្ដីសម្រេចក្នុងឆ្នាំ ២០១១ ថាការត្រួតពិនិត្យតាមផ្លូវតុលាការដោយមានលក្ខខណ្ឌ ត្រូវបានអនុញ្ញាតអនុលោមតាមវិធាន ២២៣។ ដោយពិចារណាលើស្ថានភាពបច្ចុប្បន្ននៃរឿងក្ដីនេះ ជាពិសេសមិនមានការរំពឹងសមហេតុផល ដែលចុងបណ្ដឹងសាទុក្ខនឹងត្រូវនាំមកជំនុំជម្រះក្ដីនៅពេលណាមួយខាងមុខនោះ មាត្រា ២២៣ មិនអាចអនុវត្តបានឡើយ[70]។

42. លើសពីនេះទៀត ម្ចាស់បណ្ដឹងសាទុក្ខលើកឡើងថាអង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ដោយច្រានចោលភាពអាចអនុវត្តបាននៃវិធាន ៦៥ និង ៨២។ ម្ចាស់បណ្ដឹងសាទុក្ខ បានរិះគន់អង្គជំនុំជម្រះសាលាដំបូងដែលបានសម្រេចជាស្វ័យប្រវត្តិថា ពុំមានវិធានការជាជម្រើសផ្សេងទៀតជំនួសឲ្យការឃុំខ្លួនឡើយ និងខកខានមិនបានធ្វើការថ្លឹងថ្លែងផលប្រយោជន៍របស់ភាគីដែលទទួលរងការប៉ះពាល់[71]។ ផ្ទុយពីការលើកឡើងរបស់ម្ចាស់បណ្ដឹងសាទុក្ខ ចុងបណ្ដឹងសាទុក្ខយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យមើលវិធានការដែលអាចអនុវត្តបាន អនុលោមតាមវិធាន ៦៥ និង៨២ ក្នុងនោះមានការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយភ្ជាប់ជាមួយនឹងលក្ខខណ្ឌផងដែរ។ បន្ទាប់ពីបានពិនិត្យមើលមូលហេតុនៃការដាក់វិធានការទាំងនេះ អង្គជំនុំ

[68] បណ្ដឹងសាទុក្ខភ្លាមៗរបស់ក.ស.ព កថាខណ្ឌ៧-៩ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ក.ស.ព កថាខណ្ឌ ៤។

[69] បណ្ដឹងសាទុក្ខភ្លាមៗរបស់ក.ស.ព កថាខណ្ឌ ៧ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ក.ស.ព កថាខណ្ឌ ៤។

[70] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣២-៣៣។

[71] បណ្ដឹងសាទុក្ខភ្លាមៗរបស់ក.ស.ព កថាខណ្ឌ ៨។

ជម្រះសាលាដំបូងយល់ឃើញថាពុំមានសំអាងហេតុផ្លូវច្បាប់សមស្រប ដើម្បីដាក់លក្ខខណ្ឌដូច បានចែងក្នុងវិធានផ្ទៃក្នុងឡើយ នៅពេលដែលកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទ ត្រូវ បានផ្អាកដោយគ្មានពេលកំណត់ និងនៅពេលដែលមិនមានលទ្ធភាពសមហេតុផល ដែលជនជាប់ ចោទ នឹងត្រូវយកមកជំនុំជម្រះ[72] ហើយការលើកឡើងនេះដូចគ្នានឹងជំហររបស់របស់ចុងបណ្តឹង សាទុក្ខដែរ[73]។

43. ជាចុងក្រោយ ម្ចាស់បណ្តឹងសាទុក្ខ លើកឡើងថាអង្គជំនុំជម្រះសាលាដំបូង គប្បីបានពិនិត្យមើល ទ្រឹស្តីស្តីពីអំណាចដែលភ្ជាប់មកជាមួយ ដើម្បីលាតសន្ធឹងអំណាចដាក់លក្ខខណ្ឌនៃការត្រួតពិនិត្យ តាមផ្លូវតុលាការលើជនជាប់ចោទ បន្ទាប់ពីមានសេចក្តីសម្រេចឲ្យផ្អាកកិច្ចដំណើរការនីតិវិធី[74]។

44. សញ្ញាណនៃ "យុត្តាធិការដែលភ្ជាប់មកជាមួយ" អាចអនុវត្តបាន ដោយត្រូវកំណត់អំពី "បញ្ហាផ្លូវ ច្បាប់ដែលកើតមានដោយចៃដន្យ ដែលលេចឡើងជាលទ្ធផលផ្ទាល់នៃនីតិវិធីរបស់អង្គជំនុំជម្រះ ដោយសារបញ្ហាស្ថិតក្រោមយុត្តាធិការបឋមរបស់ខ្លួន" និង "នៅពេលដែលតុលាការដទៃទៀត មិន មានសិទ្ធិអំណាចចេញសេចក្តីសម្រេចលើបញ្ហាផ្លូវច្បាប់ ដែលកើតមានដោយចៃដន្យ ដោយសារ ឧបសគ្គផ្លូវច្បាប់ ឬការរាំងស្ទះជាក់ស្តែងនានា"[75]។ អាស្រ័យហេតុនេះ តុលាការអន្តរជាតិ ជាច្រើនបានអនុវត្តយុត្តាធិការដែលភ្ជាប់មកជាមួយរបស់ខ្លួន "នៅពេលបទប្បញ្ញត្តិច្បាប់មិនចែង ច្បាស់ ឬដោយភាពចាំបាច់ ត្រូវប្រើសិទ្ធិអំណាចដើម្បីសម្រេចលើបញ្ហានេះ"[76]។ លើសពីនេះ អំណាចដែលភ្ជាប់មកជាមួយផ្តល់មធ្យោបាយឲ្យតុលាការធានាថា ជនជាប់ចោទមិនត្រូវបានដក ហូតសិទ្ធិស្របច្បាប់របស់ខ្លួន ដោយសារបញ្ហាចន្លោះប្រហោងនៃច្បាប់ឡើយ។

45. ចុងបណ្តឹងសាទុក្ខ យល់ឃើញថាទ្រឹស្តីស្តីពី "អំណាចដែលភ្ជាប់មកជាមួយ" មិនមានភាពជាប់ ពាក់ព័ន្ធក្នុងស្ថានភាពនេះ ជាវិធីមួយផ្តល់យុត្តិកម្មចំពោះការដាក់លក្ខខណ្ឌដោយបង្ខំនេះទេ។ ទីមួយ អំណាចដាក់លក្ខខណ្ឌ ឬការត្រួតពិនិត្យតាមផ្លូវតុលាការ មានចែងយ៉ាងច្បាស់ក្នុងវិធាន ២២៣ នៃ

---

[72] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣៣។

[73] ប្រតិចារិក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ១២៩-១៣៧។

[74] បណ្តឹងសាទុក្ខភ្លាមៗរបស់ក.ស.ព កថាខណ្ឌ ៩។

[75] *ក្នុងបញ្ហារឿងក្តី El Sayed លេខ* CH/AC/2010/02, សាលដីកាលើបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាសម្រេចរបស់អង្គបុរេ ជំនុំជម្រះអំពីយុត្តាធិការ និងសិទ្ធិប្តឹង ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ កថាខណ្ឌ ៤៥។

[76] *ដូចខាងលើដែរ*, កថាខណ្ឌ ៤៦។

ក្រមនីតិវិធីរដ្ឋប្បវេណីនៃកម្ពុជា និងវិធាន ៦៥ និង ៨២ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ដូចអង្គជំនុំជម្រះសាលាដំបូង បានទទួលស្គាល់ក្នុងសេចក្ដីសម្រេចដែលរងការជំទាស់របស់ខ្លួន[77] និងបានទទួលស្គាល់ដោយអង្គជំនុំជម្រះតុលាការកំពូល[78] និងប្រធានអង្គជំនុំជម្រះតុលាការកំពូល[79]។ ដូច្នេះ បញ្ហានៃការដាក់វិធានការដោយបង្ខំលើការដោះលែង ពុំមែនជាបញ្ហាផ្លូវច្បាប់ដែលកើតមានដោយចៃដន្យ ដែលមិនមានចែងក្នុងបទប្បញ្ញត្តិច្បាប់នោះទេ។ អង្គជំនុំជម្រះសាលាដំបូង បានអនុវត្តយុត្តាធិការរបស់ខ្លួន ផ្អែកលើការពិនិត្យអត្ថបទច្បាប់ដែលមាន និងយល់ឃើញមូលដ្ឋានច្បាប់សម្រាប់ការឃុំឃាំងបន្ត ឬការដាក់លក្ខខណ្ឌដោយបង្ខំចំពោះការដោះលែងចុងបណ្ដឹងសាទុក្ខ ក្នុងស្ថានភាពបច្ចុប្បន្ន មានចន្លោះប្រហោង។ អាស្រ័យហេតុនេះ សំអាងហេតុរបស់ម្ចាស់បណ្ដឹងសាទុក្ខ គប្បីត្រូវច្រានចោល។

46. ម្ចាស់បណ្ដឹងសាទុក្ខ លើកឡើងថាអង្គបុរេជំនុំជម្រះ (“អ.ប.ជ”) នៃអ.វ.ត.ក បានប្រើទ្រឹស្ដីស្ដីពី “អំណាចដែលភ្ជាប់មកជាមួយ” ហើយដូច្នេះ អង្គជំនុំជម្រះសាលាដំបូង គួរតែបានប្រើទ្រឹស្ដីនេះផងដែរ[80]។ ទោះជាយ៉ាងនេះក្ដី រាល់សេចក្ដីសម្រេចរបស់ អ.ប.ជ ដែលលើកឡើងដោយម្ចាស់បណ្ដឹងសាទុក្ខ ដោះស្រាយសិទ្ធិដែលភាគីទទួលបានក្នុងកិច្ចដំណើរការនីតិវិធី ដើម្បីធានាឲ្យមានដំណើរការល្អនៃការស្វែងរកយុត្តិធម៌។ សេចក្ដីសម្រេចរបស់អ.ប.ជ មិនពាក់ព័ន្ធនឹងបញ្ហានៃការដាក់លក្ខខណ្ឌលើជនជាប់ចោទ ដែលមានអានុភាពដាក់កំហិតលើសិទ្ធិជាសារវន្តរបស់ជនជាប់ចោទទេ។ ហេតុដូច្នេះ សេចក្ដីសម្រេចទាំងនេះ មិនអាចបង្កើតជាមូលដ្ឋានក្នុងលើកឡើងថាអង្គជំនុំជម្រះសាលាដំបូង គប្បីបានអនុវត្តទ្រឹស្ដីនោះឡើយ។

47. ការជ្រៀតជ្រែកសិទ្ធិរបស់ចុងបណ្ដឹងសាទុក្ខ៖ សិទ្ធិមានសេរីភាព និងសន្តិសុខ ឬសិទ្ធិសេរីភាពក្នុងការធ្វើដំណើរ ជាការរំលោភបំពានលើសិទ្ធិជាសារវន្តទាំងនោះ នៅពេលដែលមិនបានបំពេញ

---

[77] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣២-៣៣។

[78] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៤៥-៤៧។

[79] សម្រេចរបស់ប្រធាន អ.ជ.ត.ក លើសំណើរបស់សហព្រះរាជអាជ្ញា សុំផ្អាកសេចក្ដីសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ទំព័រ ៣ (ភាសាអង់គ្លេស)។

[80] បណ្ដឹងសាទុក្ខភ្លាមៗរបស់ក.ស.ព កថាខណ្ឌ ៩។

លក្ខខណ្ឌនៃគោលការណ៍នីត្យានុកូលភាព[81]។ ការជ្រៀតជ្រែកផ្អែកលើការអនុវត្ត "អំណាចដែលមានភ្ជាប់មកជាមួយ" អាចនឹងឈានទៅការបំពានលើសិទ្ធិរបស់ចុងបណ្ដឹងសាទុក្ខដោយជៀសមិនផុត ដោយសារមិនបានបំពេញលក្ខខណ្ឌច្បាប់។ ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា បទប្បញ្ញត្តិជាក់លាក់ក្នុងក្របខ័ណ្ឌច្បាប់របស់អ.វ.ត.ក មិនមានចែងពីមូលដ្ឋានគ្រប់គ្រាន់ ដើម្បីដាក់លក្ខខណ្ឌលើការដោះលែងក្នុងស្ថានភាពនៃរឿងក្ដីនេះទេនោះ ការដាក់លក្ខខណ្ឌទាំងនេះដោយផ្អែកលើសញ្ញាណនៃ "អំណាចដែលភ្ជាប់មកជាមួយ"មិនមានហេតុផលសមស្របឡើយ។ អាស្រ័យហេតុនេះ ចុងបណ្ដឹងសាទុក្ខ សន្និដ្ឋានថាមិនមានកំហុសផ្នែកច្បាប់ដែលតម្រូវឲ្យកែប្រែសេចក្ដីសម្រេចដែលរងការជំទាស់ឡើយ។

### *៤.៣ ការសម្រេចឲ្យដោះលែងដោយគ្មានលក្ខខណ្ឌ មិនមែនជាការភ័ន្តច្រឡំអង្គច្បាប់ទេ*

48. ចុងបណ្ដឹងសាទុក្ខ បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមិនបានភ័ន្តច្រឡំអង្គច្បាប់ នៅពេលសម្រេចឲ្យដោះលែងចុងបណ្ដឹងសាទុក្ខភ្លាមៗ និងបដិសេធមិនដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

#### *ក) ភាពខុសគ្នារវាង "ការដោះលែងដោយគ្មានលក្ខខណ្ឌ" ក្នុងន័យចង្អៀត និង "ការដោះលែងភ្លាមៗ" ក្រោមវិធានការមិនបង្ខំ*

49. ម្ចាស់បណ្ដឹងសាទុក្ខ លើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចឲ្យ "ដោះលែង [ចុងបណ្ដឹងសាទុក្ខ] ដោយគ្មានលក្ខខណ្ឌ"[82]។ ម្ចាស់បណ្ដឹងសាទុក្ខ ខកខានមិនបានញែកឲ្យឃើញពីភាពខុសគ្នារវាងការដោះលែង "ដោយគ្មានលក្ខខណ្ឌ" *ក្នុងន័យចង្អៀត* ជាមួយនឹង "ការដោះលែងភ្លាមៗ" ក្រោមវិធានការមិនបង្ខំ ដូចដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងនោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ការដាក់លក្ខខណ្ឌដោយបង្ខំលើចុងបណ្ដឹង

---

[81] សូមមើល មាត្រា៥ (១) នៃអនុសញ្ញាអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស។ ស្រដៀងគ្នានេះ សូមមើលមាត្រា២ នៃពិធីសារ លេខ ៤ នៃ អនុសញ្ញាអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស។

[82] បណ្ដឹងសាទុក្ខរបស់ក.ស.ព កថាខណ្ឌ ១០-១៦។

សាទុក្ខ គឺតាមសភាពជាក់ស្តែង ឬតាមផ្លូវច្បាប់ទំនងជាមិនអាចអនុវត្តបានឡើយ[83]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបានរំឭកដល់ចុងបណ្តឹងសាទុក្ខអំពីកាតព្វកិច្ចរបស់លោកស្រី ស្របតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង ដោយបានស្នើសុំឱ្យលោកស្រី មិនឱ្យជួបជាមួយប្រព័ន្ធសារព័ត៌មាន និងស្នើឱ្យលោកស្រីស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា[84]។

50. អង្គជំនុំជម្រះសាលាដំបូងស្នើសុំឱ្យមានផែនការដែលជាវិធានការមិនបង្ខំ ដែលអាចអនុវត្តបានចំពោះការដោះលែងចុងបណ្តឹងសាទុក្ខ។ ផែនការនេះ មានលក្ខណៈស្មុគស្មាញជាងវិធានការដែលអង្គជំនុំជម្រះបានសម្រេចកាលពីខែវិច្ឆិកា ឆ្នាំ២០១១ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចឱ្យដោះលែងចុងបណ្តឹងសាទុក្ខដោយគ្មានលក្ខខណ្ឌ[85]។ ការដោះលែងដែលសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ គឺជាការដោះលែង "ដោយគ្មានលក្ខខណ្ឌជាក់ស្តែង"[86]។

*ខ) មិនមានយុត្តិកម្មសម្រាប់ដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះទេ*

51. ចុងបណ្តឹងសាទុក្ខតវ៉ាថា មិនមានយុត្តិកម្មគតិយុត្តិណាមួយសម្រាប់ដាក់ឱ្យស្ថិតក្រោមរបបនៃការត្រួតពិនិត្យតាមផ្លូវតុលាការនោះទេ។

52. នៅក្នុងសេចក្តីសម្រេចកាលពីឆ្នាំ២០១១ អង្គជំនុំជម្រះតុលាការកំពូល បានកំណត់យកគោលបំណងចំនួនពីរដែលត្រូវអនុវត្តក្នុងពេលដំណាលគ្នា នៅពេលសម្រេចថាតើបន្តការឃុំខ្លួន ឬសម្រេចឱ្យដោះលែងជនជាប់ចោទដោយមានលក្ខខណ្ឌ។ គោលបំណងទីមួយ គឺដើម្បីធានាអំពីវត្តមានរបស់

[83] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ៣៧។

[84] *ដូចខាងលើដែរ* ទំព័រ១៩។

[85] សូមមើលសេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូងលើកទីមួយស្តីពីសម្បទា កថាខណ្ឌ៧៩-៨១។

[86] ស្រដៀងគ្នានេះដែរ សូមមើល *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brdanin and Talic* សំណុំរឿងលេខ IT-99-36-T សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទ Momir Talic បណ្តោះអាសន្ន ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០២ កថាខណ្ឌ៣២ ដោយយោងលើ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Djukic* សំណុំរឿងលេខ IT-96-20-T សេចក្តីសម្រេចបដិសេធចោលពាក្យសុំឱ្យច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចឱ្យដោះលែងបណ្តោះអាសន្ន ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦ ទំព័រ៤។

ជនជាប់ចោទនៅក្នុងពេលជំនុំជម្រះ នៅពេលមានការបន្តការជំនុំជម្រះឡើងវិញ[87]។ គោលបំណងទីពីរ "គឺដើម្បីជំរុញឲ្យប្រសើរដល់សម្បទារបស់ជនជាប់ចោទ"[88]។

53. ចុងបណ្តឹងសាទុក្ខលើកឡើងថា គោលបំណងដំបូងនៃគោលបំណងទាំងនេះ គឺមិនមានភាពពាក់ព័ន្ធនោះទេ ដោយសារតែមិនមានលក្ខខណ្ឌតម្រូវណាមួយ ដើម្បីធានាអំពីវត្តមានរបស់ចុងបណ្តឹងសាទុក្ខក្នុងការជំនុំជម្រះ ពីព្រោះតែមិនមានក្តីសង្ឃឹមសមហេតុផលណាមួយ ដែលថាលោកស្រីនឹងអាចទទួលបានការជំនុំជម្រះនោះទេ។ កាលៈទេសៈបានផ្លាស់ប្តូរជាច្រើន ចាប់តាំងពីឆ្នាំ២០១១។ ចុងបណ្តឹងសាទុក្ខ ត្រូវបានគេផ្តល់ថ្នាំពេទ្យ និងបានផ្តល់នូវកម្មវិធីព្យាបាលតាមរយៈកម្មវិធីលើកកម្ពស់សតិបញ្ញាស្មារតី ដើម្បីធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពបញ្ញាស្មារតីរបស់លោកស្រី។ នៅឆ្នាំ២០១១ គេបានទទួលស្គាល់ថាមានលទ្ធភាពតិចតួចដែលថា ជំងឺវង្វេងវង្វាន់ស្មារតី នឹងអាចប្រសើរឡើង ហើយប្រសិនបើមានការប្រសើរឡើងណាមួយនោះ គឺគ្រាន់តែមានលក្ខណៈបណ្តោះអាសន្នប៉ុណ្ណោះ។ នៅពេលដែលអ្នកជំនាញផ្នែកវេជ្ជសាស្ត្របានរកឃើញថា ការព្យាបាលមិនបាននាំឲ្យមានភាពប្រសើរឡើងណាមួយទេ ប៉ុន្តែអ្នកជំនាញបានកត់សម្គាល់ឃើញអំពីសភាពកាន់តែដុនដាបបន្ថែមទៀត។ បច្ចុប្បន្ននេះ មិនមានការព្យាបាលណាមួយដែលអាចជួយធ្វើឲ្យប្រសើរឡើងនូវដំណើរការសតិបញ្ញាស្មារតីរបស់ចុងបណ្តឹងសាទុក្ខនោះទេ។ អ្នកជំនាញផ្នែកវេជ្ជសាស្ត្របានសង្កត់ធ្ងន់ថា ស្ថានភាពរបស់លោកស្រី នឹងបន្តធ្លាក់ដុនដាប ដោយសារតែជំងឺវង្វេងវង្វាន់ស្មារតី (Alzheimer) មានស្ថានភាពចុះដុនដាប និងវិវឌ្ឍន៍ទៅមុខ ដែលជំងឺនេះពាក់ព័ន្ធនឹងការបំផ្លាញកោសិកាខួរក្បាល ដែលមិនមានអ្វីយកមកជំនួសបាននោះទេ[89]។ អ្នកជំនាញបានផ្តល់សក្ខីកម្មថា ខ្លួនមិនបានដឹងអំពីករណីណាមួយ ដែលបុគ្គលមានរោគវិនិច្ឆ័យនៃជំងឺវង្វេងវង្វាន់ស្មារតីអាចមានសភាពល្អប្រសើរឡើង នៅពេលការព្យាបាលទាំងអស់ដែលអាចមាន ដូចជាការផ្តល់ថ្នាំ ត្រូវបានប្រើប្រាស់អស់ហើយនោះ[90]។ ឱសថថ្មី និងគុណប្រយោជន៍ដែលអាចមាន នឹងត្រូវធ្វើការសាកល្បងនៅមន្ទីរពិសោធន៍ជាច្រើនឆ្នាំ មុនពេលដែលឱសថនោះអាចផលិតឲ្យប្រើប្រាស់។ ថ្មីៗនេះ ការសាកល្បងថ្នាំសំខាន់ចំនួនពីរប្រភេទសម្រាប់ព្យាបាលជំងឺ Alzheimer ដែលនៅក្នុងការសាកល្បង

---

[87] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ៤១។

[88] *ដូចខាងលើដែរ* កថាខណ្ឌ៤១-៤២។

[89] ប្រតិចារឹកចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២ ទំព័រ៥១, ៩៦។

[90] *ដូចខាងលើដែរ* ទំព័រ៧៥។

ព្យាបាលជំងឺវង្វេងវង្វាន់ស្មារតីនៅដំណាក់ចុងក្រោយ ត្រូវបានគេរាយការណ៍អំពីលទ្ធផលធ្វើឱ្យខកបំណង ហើយការពិសោធន៍នោះត្រូវបានបញ្ឈប់។ ជាលទ្ធផល ក្រុមហ៊ុនឱសថនានា បានដកខ្លួនចេញពីការវិនិយោគរបស់ពួកគេ ក្នុងការស្រាវជ្រាវដែលមិនបានទទួលជោគជ័យ[91]។ ការអះអាងដែលថា ការព្យាបាលថ្មីមួយចំនួនអាចនឹងរកឃើញនៅក្នុងជីវិតរស់នៅរបស់ចុងបណ្តឹងសាទុក្ខ ដូចដែលអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់យ៉ាងត្រឹមត្រូវ[92] គឺគ្រាន់តែជាការប៉ាន់ស្មានប៉ុណ្ណោះ។ តុលាការមិនអាចដោះស្រាយរឿងក្តី នៅក្នុងស្ថានភាពជាការប៉ាន់ស្មានជាមុននោះទេ។

54. គោលបំណងទីពីរ មិនអាចបំពេញបាននោះទេ ពីព្រោះតែដំណើរការសតិបញ្ញាស្មារតីរបស់ចុងបណ្តឹងសាទុក្ខ មិនអាចធ្វើឱ្យប្រសើរឡើង សូម្បីតែក្នុងរយៈពេលបណ្តោះអាសន្នក៏ដោយ។ ចាប់តាំងពីសវនាការនៅឆ្នាំ ២០១១ វិធានការទាំងអស់ដែលអាចមាន ត្រូវបានអនុវត្តក្នុងលក្ខណៈមួយដ៏ល្អ ដើម្បីព្យាយាមធ្វើឱ្យប្រសើរឡើងនូវបញ្ញាស្មារតីរបស់លោកស្រី[93]។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងយ៉ាងត្រឹមត្រូវ "ដំណើរការនីតិវិធីព្រហ្មទណ្ឌ នៅតែមានអានុភាពដដែល ដោយហេតុថា ភាពប្រសើរឡើងអាចកើតមានក្នុងពេលមួយដែលចាំបាច់ក្នុងការសម្រួលដល់ការជំនុំជម្រះក្តីព្រហ្មទណ្ឌនាពេលបន្ទាប់"[94]។ ចុងបណ្តឹងសាទុក្ខ លើកឡើងថា មានភស្តុតាងពិតប្រាកដបង្ហាញថា ចុងបណ្តឹងសាទុក្ខមិនអាចមានសភាពល្អប្រសើរឡើងវិញបានទេ។ ហេតុដូច្នេះយុត្តិកម្មដើម្បីដាក់លក្ខខណ្ឌនៅពេលដោះលែង នឹងមិនមាននោះទេ។

55. ដោយសារតែមិនមានការសង្ឃឹមសមហេតុផលថា ចុងបណ្តឹងសាទុក្ខអាចមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមនៅក្នុងការជំនុំជម្រះនាពេលអនាគត អង្គជំនុំជម្រះសាលាដំបូងសម្រេចផ្អាកកិច្ចដំណើរ

---

[91] សូមមើល "ក្រុមហ៊ុនឱសថធំៗ ឈប់ស្វែងរកវិធីព្យាបាលជំងឺ Alzheimer" *សារព័ត៌មាន The Independent* ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១២ (មាននៅគេហទំព័រ http://www.independent.co.uk/life-style/health-and-families/health-news/drug-giants-give-up-on-alzheimers-cure-8153606.html)។ សូមមើលផងដែរ "ការសាកល្បងថ្នាំ Alzheimer ត្រូវបានផ្អាកក្រោយពេលទទួលបានលទ្ធផលមិនល្អ" *សារព័ត៌មាន The New York Times* ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២ (មាននៅគេហទំព័រ http://www.nytimes.com/2012/08/07/business/alzheimers-drug-trials-halted.html?_r=1&)។

[92] សេចក្តីសម្រេចដែលទទួលរងការជំទាស់ កថាខណ្ឌ២៩។

[93] សូមមើលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ៣៨ ដែលអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "អ.វ.ត.ក តម្រូវឱ្យប្រើឱ្យអស់នូវរាល់វិធានការដែលអាចមានក្នុងការជួយឱ្យជនជាប់ចោទប្រសើរឡើងដើម្បីចូលរួមសវនាការ"

[94] *ដូចខាងលើដែរ* កថាខណ្ឌ៣៧។

ការនីតិវិធីដោយមិនកំណត់រយៈពេល[95]។ ជាក់ស្តែង ការផ្អាកដំណើរការនីតិវិធីនេះ នឹងមិនត្រូវបានបដិសេធចោលនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Lubanga* បានលើកឡើងយ៉ាងច្បាស់ថា "ប្រសិនបើមានការសម្រេចឲ្យផ្អាកដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ និងមិនអាចបដិសេធចោលបាននោះ ជនជាប់ចោទនឹងត្រូវដោះលែង ពីព្រោះតែការបន្តឃុំខ្លួន មិនជាប់ទាក់ទងនឹងការអនុវត្តយុត្តាធិការផ្នែកព្រហ្មទណ្ឌរបស់តុលាការទៀតទេ"[96]។ អង្គជំនុំជម្រះតុលាការកំពូលអាចសម្រេចដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ នៅពេលដែលការផ្អាកដំណើរការនីតិវិធី គឺមានលក្ខខណ្ឌ និងនៅពេលដែលការវិវឌ្ឍបន្ថែម ទំនងជាបង្ហាញថា ការផ្អាកនេះ អាចលុបចោលវិញនៅក្នុងអនាគតខាងមុខឆាប់ៗនេះ[97]។

56. ហេតុដូច្នេះ មិនមានយុត្តិកម្មណាមួយដើម្បីសម្រេចដាក់ចុងបណ្តឹងសាទុក្ខឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះទេ។ អង្គជំនុំជម្រះសាលាដំបូង មិនបានភ័ន្តច្រឡំអង្គច្បាប់ក្នុងការសម្រេចថា "មិនមានមូលដ្ឋានគតិយុត្តិច្បាស់លាស់ ដើម្បីកំណត់លក្ខខណ្ឌដោយបង្ខំ ឬដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ តាមទម្រង់ផ្សេងៗលើជនជាប់ចោទនៅពេលដោះលែងទេ"[98]។

*គ) គ្មានបទដ្ឋានអនុវត្តអន្តរជាតិស្តីពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ផ្លូវតុលាការ*

57. ម្ចាស់បណ្តឹងសាទុក្ខបានលើកទឡ្ហីករណ៍ថា ពុំមានមូលដ្ឋានគតិយុត្តនៅក្រោមយុត្តិសាស្ត្រ និងបទដ្ឋានអនុវត្តអន្តរជាតិសម្រាប់ការពិចារណា អំពីការដាក់លក្ខខណ្ឌកំហិតចំពោះការដោះលែងជនជាប់ចោទបណ្តោះអាសន្ន នៅពេលដែលការបន្តការឃុំខ្លួនជនជាប់ចោទ ត្រូវបានសម្រេចលើកចោលរួចទៅហើយនោះ[99]។

---

[95] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ២៨។

[96] *រឿងក្តី* *Lubanga* op. cit. កថាខណ្ឌ៣៦។

[97] *ដូចខាងលើដែរ* កថាខណ្ឌ៣៧។

[98] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ៣៣។

[99] បណ្តឹងសាទុក្ខរបស់ ក.ស.ព កថាខណ្ឌ ១១។

58. រឿងក្តីទាំងឡាយ ដែលម្ចាស់បណ្តឹងសាទុក្ខបានដកស្រង់យកមកនេះ[100] ដើម្បីផ្តល់ជាយុត្តិកម្មអំពីអត្ថិភាពនៃបទដ្ឋានអន្តរជាតិ ពាក់ព័ន្ធជាសំខាន់បំផុតនោះគឺទៅនឹងកាលៈទេសៈនៃអង្គហេតុផ្សេងៗគ្នា។ ហេតុដូច្នេះ រឿងក្តីទាំងនេះពុំអាចយកមកធ្វើជាមូលដ្ឋានដើម្បីគាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួននៅក្នុងរឿងក្តីបច្ចុប្បន្ននេះឡើយ។ នៅក្នុង*រឿងក្តី Kovacevic* អង្គជំនុំជម្រះបានបង្គាប់ឲ្យដោះលែងជនជាប់ចោទបណ្តោះអាសន្នទៅតាមសំណើរបស់ក្រុមមេធាវីការពារក្តី ដើម្បីអនុញ្ញាតឲ្យជននេះទទួលការព្យាបាលបានគ្រប់គ្រាន់នៅក្នុងស្ថាប័នជំនាញ ដោយផ្អែកលើមូលដ្ឋានថា លក្ខខណ្ឌតម្រូវនានានៃវិធាន៦៥ ត្រូវបានបំពេញ ពោលគឺ ជនជាប់ចោទនឹងបង្ហាញខ្លួននៅក្នុងពេលជំនុំជម្រះក្តី។ អ្នកជំនាញផ្នែកវេជ្ជសាស្ត្រយល់ឃើញថា ការព្យាបាលតាមមធ្យោបាយនេះ អាចធ្វើឲ្យស្ថានភាពរបស់ជននេះមានភាពប្រសើរឡើងច្រើន ហើយដោយផ្អែកតាមមូលដ្ឋាននេះ ហើយទើបអង្គជំនុំជម្រះសម្រេចពន្យារកិច្ចដំណើរការនីតិវិធីចំនួន ៦ ខែ ដោយហេតុថា ការជំនុំជម្រះនឹងមានលទ្ធភាពរៀបចំឡើងនៅក្នុងពេលអនាគតខាងមុខឆាប់ៗ[101]។ ដូចគ្នានេះដែរនៅក្នុង *រឿងក្តី Talic* អង្គជំនុំជម្រះក៏បានបង្គាប់ឲ្យដោះលែង Talic ជាបណ្តោះអាសន្នទៅតាមសំណើរបស់ក្រុមមេធាវីការពារក្តីដូចគ្នា ដោយផ្អែកលើមូលដ្ឋានថា ស្ថានភាពវេជ្ជសាស្ត្ររបស់គាត់ "មានវិសមិតភាពជាមួយនឹងស្ថានភាពនៃការបន្តការឃុំខ្លួន"[102]។ អង្គជំនុំជម្រះបានដាក់ភ្ជាប់លក្ខខណ្ឌបង្ខំចំពោះការដោះលែងឲ្យមានសេរីភាព ដើម្បីកុំឲ្យប៉ះពាល់ដល់ការជំនុំជម្រះដែលកំពុងធ្វើឡើង និងដោយសារវាអាចមានឱកាសដែលថា ជនជាប់ចោទនឹងមានសម្បទាចូលរួមការជំនុំជម្រះក្តីនៅក្នុងពេលខាងមុខ[103]។ នៅក្នុង*រឿងក្តី Djukic* អង្គជំនុំជម្រះបានដោះលែងជនជាប់ចោទជាបណ្តោះអាសន្ន ដោយផ្អែកលើមូលដ្ឋានមនុស្សធម៌ ដោយហេតុថា ការឃុំខ្លួនជនជាប់ចោទមានវិសមភាពជាមួយនឹងស្ថានភាពវេជ្ជសាស្ត្ររបស់ជននេះ។ អង្គជំនុំជម្រះបានដាក់លក្ខខណ្ឌក្នុងកម្រិតអប្បបរមានៅពេលដោះលែងជនជាប់ចោទ ដើម្បីធានាវត្តមានរបស់ជននេះក្នុងពេលជំនុំ

---

[100] បណ្តឹងសាទុក្ខរបស់ ក.ស.ព កថាខណ្ឌ ១១-១២ លេខយោងជើងទំព័រ ៣២។

[101] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Kovacevic* សំណុំរឿងលេខ IT-01-42/2-I សេចក្តីសម្រេចលើការដោះលែងឲ្យមានសេរីភាពបណ្តោះអាសន្ន ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០០៤ ទំព័រ ២។

[102] *រឿងក្តី Brdanin និង Talic* op. cit. កថាខណ្ឌ ៣២។

[103] *ដូចខាងលើដែរ* កថាខណ្ឌ ៣៤។

ជម្រះក្តី[104]។ រឿងក្តីចុងក្រោយគឺ*រឿងក្តី Stanisic* អង្គជំនុំជម្រះបានបង្គាប់ឱ្យដោះលែងជនជាប់ចោទ Stanisic និង Simatovic ជាបណ្តោះអាសន្ន ដោយមានលក្ខខណ្ឌ[105]។ Stanisic មានជំងឺបាក់ទឹកចិត្តធ្ងន់ធ្ងរ ហេតុដូច្នេះ អង្គជំនុំជម្រះបានពន្យារកិច្ចដំណើរការនីតិវិធីចំនួនរយៈពេលអប្បបរមា ៣ ខែ[106]។ Simatovic ត្រូវបានដោះលែងឱ្យមានសេរីភាព ពីព្រោះតែមានការពន្យារពេលការចាប់ផ្តើមការជំនុំជម្រះក្តី[107]។ ការជំនុំជម្រះលើជនជាប់ចោទ Stanisic និង Simatovic ត្រូវបានចាប់ផ្តើមឡើងវិញក្នុងពេលមួយសមស្រប និងអង្គជំនុំជម្រះបានបង្គាប់ឱ្យនាំជនជាប់ចោទទាំងពីរវិលត្រឡប់មកមន្ទីរឃុំឃាំងរបស់តុលាការ ICTYវិញ[108]។

59. ដូចបានកត់សម្គាល់ដោយអង្គជំនុំជម្រះសាលាដំបូង[109] ចំពោះរឿងក្តីដូចបានលើកឡើងខាងលើ គ្មានរឿងក្តីណាមួយ ផ្តល់នូវមូលដ្ឋាន ឬការគាំទ្រផ្លូវច្បាប់ឱ្យដាក់លក្ខខណ្ឌបង្ខំនៅពេលដោះលែងបណ្តោះអាសន្ន ដោយហេតុថា រឿងក្តីទាំងនេះពុំមានលក្ខខណ្ឌស្រដៀងគ្នាទៅនឹងរឿងក្តីរបស់ជនជាប់ចោទបច្ចុប្បន្នឡើយ។ ករណីដែលថា ជនជាប់ចោទមានជំងឺដោយព្យាបាលពុំជាសះស្បើយ មិនមែនមានន័យដោយស្វ័យប្រវត្តិថា ជនជាប់ចោទនឹងពុំមានសម្បទាក្នុងការចូលរួមការជំនុំជម្រះនោះទេ។ ស្រដៀងគ្នានេះដែរ ករណីជំងឺផ្នែកស្មារតី បានរួមបញ្ចូលទាំងលទ្ធភាពជាក់ស្តែងនៃស្ថានភាពដែលកំពុងត្រូវបានព្យាបាល។ ចំពោះរឿងក្តីដែលបានដកស្រង់មកនេះ ពុំមានរឿងក្តីណាមួយពាក់ព័ន្ធនឹងករណីដែលជនជាប់ចោទមានជំងឺវង្វេងវង្វាន់ស្មារតីនោះទេ។ ជំងឺនេះមានលក្ខណៈពិសេស ដោយសារវាចេះតែវិវឌ្ឍន៍ដុនដាបទៅមុខ ហើយវាប៉ះពាល់ទៅនឹងមុខងារសតិបញ្ញាស្មារតី ហើយពុំមានលទ្ធភាពអាចព្យាបាលបាន។ រាល់សំណើសុំដោះលែងឱ្យមានសេរីភាព

---

[104] *រឿងក្តី Djukic* op. cit. ទំព័រ ៥។

[105] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Stanisicនិង Simatovic* សំណុំរឿងលេខ IT-03-69-PT សេចក្តីសម្រេចលើការដោះលែងឱ្យមានសេរីភាពបណ្តោះអាសន្ន ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨ កថាខណ្ឌ ៦៥-៦៦។

[106] *ដូចខាងលើដែរ* កថាខណ្ឌ ៦២។

[107] *ដូចខាងលើដែរ* កថាខណ្ឌ ៦៦។

[108] សូមមើល *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Stanisic និង Simatovic*, សំណុំរឿងលេខ IT-03-69-PT, សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាដែលសុំបដិសេធការដោះលែង Jovica Stanisic បណ្តោះអាសន្ន និងការវាយតម្លៃឡើងវិញពីបញ្ហាសុខភាពរបស់គាត់ និងការបដិសេធការដោះលែង Franko Simatovic បណ្តោះអាសន្ន, ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៩, ទំព័រ ៦-៨ (ភាសាអង់គ្លេស)។

[109] សេចក្តីសម្រេចដែលរងការជំទាស់, កថាខណ្ឌ ៣៧។

នីមួយៗ ត្រូវផ្អែកលើអង្គហេតុ និងត្រូវសម្រេចដោយផ្អែកលើគ្រប់កាលៈទេសៈទាំងអស់នៅក្នុងរឿងក្តីនោះ[110]។ ដោយសារហេតុផលនេះ វាគ្មានន័យអ្វីក្នុងការអះអាងថា "បទដ្ឋានអនុវត្ត" មានអត្ថិភាពនៅក្នុងច្បាប់អន្តរជាតិ សម្រាប់ដាក់លក្ខខណ្ឌកំហិតនៅពេលដោះលែងឲ្យមានសេរីភាព។ បទដ្ឋានអនុវត្តយុត្តិធម៌នោះ គឺទាមទារឲ្យពិចារណាលើខ្លឹមសារនៃរឿងក្តីនីមួយៗ អនុលោមតាមច្បាប់។

60. ម្ចាស់បណ្តឹងសាទុក្ខលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង "បានភ័ន្តច្រឡំជាមូលដ្ឋាននូវគោលបំណង និងយុត្តិកម្មសម្រាប់ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ" និងដោយបានលើកឡើងថា គោលបំណងតែមួយគត់នៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងអំឡុងពេលនៃការផ្អាកកិច្ចដំណើរការនីតិវិធីនេះ គឺដើម្បីធានាវត្តមានរបស់ជនជាប់ចោទនៅក្នុងពេលជំនុំជម្រះ នៅពេលដែលការជំនុំជម្រះចាប់ផ្តើមឡើងវិញ[111]។ នៅក្នុងពេលជាមួយគ្នានេះដែរ ម្ចាស់បណ្តឹងសាទុក្ខអះអាងថា "ការធានាអំពីវត្តមានរបស់ជនជាប់ចោទក្នុងពេលសវនាការនៅតែជាគោលបំណងចម្បង នៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ [...] [ប៉ុន្តែ] នេះជាគោលបំណងស្របច្បាប់តែមួយគត់ដែលត្រូវយកមកអនុវត្ត"[112]។

61. ម្ចាស់បណ្តឹងសាទុក្ខទទួលស្គាល់ថា បន្ថែមលើការធានាវត្តមានរបស់ជនជាប់ចោទក្នុងពេលសវនាការ ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ក៏អាចមានយុត្តិកម្មផងដែរ ដោយសារវាជាមធ្យោបាយមួយដើម្បីការពារបុគ្គលផ្សេងទៀត ជាពិសេស ជនរងគ្រោះ និងសាក្សី។ លក្ខខណ្ឌទាំងពីរនេះ ជាលក្ខខណ្ឌត្រួត និងស៊ីសង្វាក់គ្នា[113]។ នេះជាបទដ្ឋានអនុវត្តទូទៅនៅចំពោះមុខ

---

[110] សូមមើល *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Hadzihasanovic និងអ្នកដទៃទៀត,* សំណុំរឿងលេខ IT-01-47-PT, សេចក្តីសម្រេចដោះលែង Amir Kubura បណ្តោះអាសន្ន, ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០១, កថាខណ្ឌ ៧; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Boskoski និង Tarculovski*, សំណុំរឿងលេខ IT-04-82-AR65.1, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធសំណើរបស់ Johan Tarculovski ដែលសុំការដោះលែងបណ្តោះអាសន្ន, ចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០០៥, កថាខណ្ឌ ៧។

[111] សារណាបន្ថែមរបស់ ក.ស.ព, កថាខណ្ឌ ៤។

[112] *ដូចខាងលើដែរ,* កថាខណ្ឌ ៥។

[113] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Nsengimana*, សំណុំរឿងលេខ ICTR-01-69-I សេចក្តីសម្រេចលើសំណើរបស់ Nsengimana ដែលសុំកំណត់កាលបរិច្ឆេទសម្រាប់សន្និសីទមុនការជំនុំជម្រះ កាលបរិច្ឆេទនៃការចាប់ផ្តើមសវនាការ និងការដោះលែងបណ្តោះអាសន្ន, ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០៥, កថាខណ្ឌ ១៧ ដែលដកស្រង់ចេញពី *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalic និងអ្នក*

អ.វ.ត.ក[114] និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា[115]។ ករណីនេះគឺដោយសារតែលក្ខណៈ និងបញ្ហាសន្តិសុខ ដូចបានទាមទារឡើងនេះ គឺពាក់ព័ន្ធនឹងមូលដ្ឋានដែលការឃុំខ្លួនបណ្តោះអាសន្នបានផ្អែកលើ ពោលគឺ ការជំនុំជម្រះនឹងធ្វើឡើងនាពេលខាងមុខ[116]។ ទោះបីជាយ៉ាងនេះក្តី ម្ចាស់បណ្តឹងសាទុក្ខ ខកខានពុំទទួលស្គាល់ថា ពុំមានមូលដ្ឋានផ្លូវច្បាប់សម្រាប់ការដាក់លក្ខខណ្ឌនៅពេលដោះលែងឱ្យមានសេរីភាពឡើយ នៅពេលដែលការជំនុំជម្រះនាពេលខាងមុខ នឹងពុំធ្វើឡើង ឬទំនងជាពុំអាចធ្វើទៅរួចយ៉ាងពិតប្រាកដ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី *Lubanga* បានសម្រេចថា អង្គជំនុំជម្រះអាចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនៅក្នុងស្ថានភាពមួយដែលការវិវឌ្ឍបន្ថែម ចាប់តាំងពីការដាក់ការផ្អាកដោយមានលក្ខខណ្ឌ ទំនងជាបង្ហាញថា ការផ្អាកនេះអាចលុបចោលវិញនៅក្នុងអនាគតខាងមុខឆាប់ៗនេះ[117]។ ករណីនេះគឺមិនដូចនឹងករណីបច្ចុប្បន្នឡើយ ដោយសារតែជនជាប់ចោទត្រូវបានរកឃើញថាពុំមានសម្បទាជាអចិន្ត្រៃយ៍ ហើយគេទទួលស្គាល់ថា កិច្ចដំណើរការនីតិវិធីជំនុំជម្រះប្រឆាំងនឹងជនជាប់ចោទ នឹងពុំអាចធ្វើឡើងវិញឡើយ។ នៅក្នុងការដាក់វិធានការ**បង្ខំ** អង្គជំនុំជម្រះ

---

*ដទៃទៀត,* សំណុំរឿងលេខ IT-96-21-T, សេចក្តីលើសំណើសុំដោះលែងបណ្តោះអាសន្នដែលបានដាក់ដោយជនជាប់ចោទ Zejnil Delalic, ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៦, កថាខណ្ឌ ១។

[114] វិធាន ៦៥ នៃវិធានផ្ទៃក្នុងចែងថាសហចៅក្រមស៊ើបអង្កេតអាចចេញបង្គាប់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និង "កំណត់លក្ខខណ្ឌមួយចំនួន ដើម្បីធានាអំពីវត្តមានរបស់ជនត្រូវចោទក្នុងកិច្ចដំណើរការនីតិវិធី និងការពារអ្នកដទៃទៀត"។

[115] វិធាន៦៥ (គ) នៃវិធានស្តីពីនីតិវិធីនិងការដាក់ភ័ស្តុតាងនៃតុលាការ ICTY ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២។ វិធាន ៦៥(គ) នៃវិធានស្តីពីនីតិវិធីនិងការដាក់ភ័ស្តុតាងនៃតុលាការ ICTR ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០០៩។ វិធាន ៦៥(ខ) នៃវិធានស្តីពីនីតិវិធីនិងការដាក់ភ័ស្តុតាងនៃតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២។ សូមមើលផងដែរ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Boskoski និង Tarculovski* សំណុំរឿងលេខ IT-04-82-AR65.4 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំរបស់ Johan Tarculovski ស្តីពីការដោះលែងបណ្តោះអាសន្ន ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧ កថាខណ្ឌ ១៤។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Norman *និង អ្នកផ្សេងទៀត* សំណុំរឿងលេខ SCSL-04-14-T, Fofana – សេចក្តីសម្រេចលើពាក្យសុំដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អនុលោមតាមវិធាន ៦៥ ចុះថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០៤ កថាខណ្ឌ ៦២។

[116] P. Van Dijk, F. Van Hoof, A. Van Rijn and L. Zwaak (eds.) ទ្រឹស្តី និងបទដ្ឋានអនុវត្តចំពោះអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (*Theory and Practice of the European Convention on Human Rights)* (Intersentia Antwerpen Oxford, 2006) ទំព័រ ៤៩៧-៤៩៨។

[117] *រឿងក្តី* *Lubanga*, op. cit., កថាខណ្ឌ ៣៧។

សាលាដំបូងអនុវត្តយុត្តាធិការព្រហ្មទណ្ឌរបស់ខ្លួន ដើម្បីធានាវត្តមានរបស់ជនជាប់ចោទនៅក្នុងពេលសវនាការ និងដើម្បីការពារបុគ្គលផ្សេងទៀត។ តាមន័យបង្កប់នៃពាក្យគុណនាម ដែលម្ចាស់បណ្តឹងសាទុក្ខបានយកមកប្រើប្រាស់ វិធានការទាំងនេះមានលក្ខណៈជាការដាក់ទណ្ឌកម្ម។

62. លើសពីនេះ អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ ដោយមានការយល់ច្រឡំអំពីបច្ច័យនៃសេចក្តីសម្រេចនៅក្នុងរឿងក្តី *Talic* ដូចដែលម្ចាស់បណ្តឹងសាទុក្ខបានអះអាងឡើយ[118]។ ទីមួយ អង្គហេតុដែលថា អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថាមានការខ្វែងគំនិតគ្នារវាងអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ស្តីអំពីសម្បទាក្នុងការចូលរួមសវនាការរបស់ *Talic* ជាជាងការបន្តការឃុំខ្លួន មិនធ្វើឲ្យទៅជាមោឃៈនូវសេចក្តីសម្រេចដែលរងការជំទាស់នោះទេ ហើយវាក៏មិនបណ្តាលភាពមិនយុត្តិធម៌នោះដែរ ពីព្រោះសេចក្តីពិស្តារពិសេសនេះ ពុំមានជាប់ទាក់ទងទៅនឹងលទ្ធផលនៃសេចក្តីសម្រេចដែលរងការជំទាស់ទាំងមូលនោះទេ។ ទីពីរ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងដោយមិនត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញភាពខុសគ្នារវាងលក្ខខណ្ឌរឹតត្បិតនានាដែលអនុវត្តលើ *Talic* ដោយហេតុផលនៃ "លទ្ធភាពដែលគាត់អាចចូលរួមសវនាការបន្តបន្ទាប់ទៀត" ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូង ICTY បានដាក់លក្ខខណ្ឌដោយបានដឹងយ៉ាងច្បាស់លាស់ថា *Talic* នឹងមិនមានជីវិតរស់នៅរហូតដល់ពេលដែលការជំនុំជម្រះក្តីរបស់គាត់បញ្ចប់ឡើយ។ ជាការពិត អង្គជំនុំជម្រះសាលាដំបូង ICTY បានសម្រេចថា លក្ខខណ្ឌនានា "មានលក្ខណៈចាំបាច់ និងសមស្រប" ដើម្បីធានាថា ការជំនុំជម្រះក្តីដែលកំពុងធ្វើឡើងនឹងមិនរងនូវព្យសនកម្មណាមួយឡើយ ទោះក្នុងករណីណាក៏ដោយ"[119] ដើម្បីធានាថា គាត់បានទទួលនូវការព្យាបាលផ្នែកវេជ្ជសាស្ត្រគ្រប់បែបយ៉ាងដែលគាត់ត្រូវការ[120] និងសំខាន់បំផុតដើម្បីធានាថា លក្ខខណ្ឌកំណត់ទាំងឡាយនៃវិធាន ៦៥ ដែលចែងអំពីការដោះលែង ត្រូវបានប្រតិបត្តិតាម រួមទាំងធានាអំពីវត្តមានបន្តបន្ទាប់របស់គាត់នៅក្នុងសវនាការផងដែរ[121]។ ចំពោះទស្សនៈវិស័យពិសេសនេះ អង្គជំនុំជម្រះសាលាដំបូង ICTY បានលើកឡើងថា ក្នុងករណីគាត់ជាសះស្បើយគ្រប់គ្រាន់អាចបន្តចូលរួមសវនាការ

[118] បណ្តឹងសាទុក្ខរបស់ ក.ស.ព កថាខណ្ឌ ១៣ ជើងទំព័រ ៤១។

[119] *Brdanin and Talic*, op. cit., កថាខណ្ឌ ៣៤-៣៥។

[120] ដូចខាងលើ កថាខណ្ឌ ៣៦។

[121] ដូចខាងលើ កថាខណ្ឌ ៣៦-៣៨។

លក្ខខណ្ឌទាំងឡាយចាំបាច់ត្រូវយកមកអនុវត្ត[122]។ ដូចនេះ ម្ចាស់បណ្តឹងសាទុក្ខលើកឡើងខុសអំពីសេចក្តីសម្រេចក្នុងរឿងក្តី *Talic* និងពុំមានកំហុសអង្គច្បាប់ និងកំហុសអង្គហេតុណាមួយត្រូវបានប្រព្រឹត្តដោយអង្គជំនុំជម្រះសាលាដំបូងឡើយ។

63. មានការលើកឡើងដោយម្ចាស់បណ្តឹងសាទុក្ខថា "ការដោះលែងដោយគ្មានលក្ខខណ្ឌ ហាក់ដូចជាត្រូវបានយកមកអនុវត្តជាករណីពិសេស ដោយផ្អែកតែទៅលើហេតុផលខាងមនុស្សធម៌ នៅក្នុងករណីដែលស្ថានភាពសុខភាពរបស់ជនជាប់ចោទស្ថិតក្នុងដំណាក់កាល*ចុងក្រោយបំផុត*" និងថាសេចក្តីសម្រេចដែលរងការជំទាស់ មិនបានបង្ហាញអំពីមូលហេតុខាងមនុស្សធម៌ ដែលអាចយកមកធ្វើជាមូលដ្ឋានផ្លូវច្បាប់គ្រប់គ្រាន់ ដើម្បីដោះលែងដោយគ្មានលក្ខខណ្ឌចាប់បង្ខំឡើយ[123]។ ចុងបណ្តឹងសាទុក្ខអះអាងជាថ្មីថា ការដោះលែងដែលត្រូវបានបង្គាប់ដោយអង្គជំនុំជម្រះសាលាដំបូងពុំមែនជាការដោះលែងដោយគ្មានលក្ខខណ្ឌនោះទេ ប៉ុន្តែជាការដោះលែងបន្ទាន់ដោយគ្មានវិធានការ ចាប់បង្ខំ[124]។ ទោះក្នុងករណីណាក៏ដោយ ហេតុផលនៅពីក្រោយការដាក់លក្ខខណ្ឌទាំងឡាយ ដូចដែលបានលើកឡើងដោយអង្គជំនុំជម្រះតុលាការកំពូល នៅក្នុងកថាខណ្ឌដដែល ដែលបានដកស្រង់ដោយម្ចាស់បណ្តឹងសាទុក្ខ[125] គឺដើម្បីធានាអំពីវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការ។ ចំណុចសំខាន់ដែលត្រូវកត់សម្គាល់គឺថា ស្ថានភាពជំងឺនៅដំណាក់កាលចុងក្រោយ *មិនពិតជា*រាំងមិនឲ្យជនជាប់ចោទមានសម្បទាក្នុងការឆ្លើយទៅនឹងបទចោទ និង/ឬ ក្នុងការចូលរួមសវនាការឡើយ។ អ្នកជំងឺ ដែលស្ថិតក្នុងស្ថានភាពចុងក្រោយអាចនឹងរស់រានមានជីវិតបានច្រើនឆ្នាំទៀត។ ដូចនេះ ដូចដែលម្ចាស់បណ្តឹងសាទុក្ខបានកត់សម្គាល់[126] ជនជាប់ចោទដែលមានជំងឺក្នុងស្ថានភាពចុងក្រោយត្រូវបានអនុញ្ញាតធ្វើការដោះលែងជាបណ្តោះអាសន្ន ដោយមានលក្ខខណ្ឌចាប់បង្ខំ ដោយគិតអំពីលទ្ធភាពនៃការជំនុំជម្រះក្តីដែលអាចនឹងត្រូវធ្វើឡើង។ ការធ្វើយុត្តិកម្មសម្រាប់ការដោះលែងចុងបណ្តឹងសាទុក្ខដោយគ្មានលក្ខខណ្ឌ ដោយមូលហេតុមនុស្សធម៌ កើតចេញមកពីអលទ្ធភាពរបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ។ ដូចនេះ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខត្រូវតែច្រានចោល។

[122] ដូចខាងលើ កថាខណ្ឌ ៤០-៤២។

[123] បណ្តឹងសាទុក្ខរបស់ ក.ស.ព កថាខណ្ឌ ១៣ ដោយយោង សាលដីការបស់ អ.ជ.ត.ក កថាខណ្ឌ ២៥។

[124] សូមមើល កថាខណ្ឌ ៤៩ ដល់ ៥០ នៃចម្លើយតបនេះ។

[125] សាលដីការបស់ អ.ជ.ត.ក កថាខណ្ឌ ២៥។

[126] បណ្តឹងសាទុក្ខរបស់ ក.ស.ព កថាខណ្ឌ ១៣។

*ឃ. វិធានការចាប់បង្ខំដែលបានស្នើឡើងមិនមានលក្ខណៈសមាមាត្រ មិនសមស្រប និងមិនចាំបាច់*

64. ម្ចាស់បណ្តឹងសាទុក្ខលើកឡើងថា ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ការកម្រិតព្រំដែននៃសិទ្ធិ ទាំងឡាយអាចត្រូវបានធ្វើយុត្តិកម្ម ប្រសិនបើវិធានការនានាដែលបានធ្វើឡើងមានលក្ខណៈ សមស្រប ចាំបាច់ និងសមាមាត្រនៅក្នុងកាលៈទេសៈទាំងនោះ។ ម្ចាស់បណ្តឹងសាទុក្ខលើកឡើងថែមទៀតថា ការដាក់លក្ខខណ្ឌរឹតត្បិតលើការដោះលែងជនជាប់ចោទ ដែលពុំមានសម្បទាក្នុងការចូលរួមសវនាការ បំពេញបន្ថែមទៅនឹង "លក្ខណវិនិច្ឆ័យនៃគោលការណ៍សមាមាត្រ" នេះ[127]។

65. ចុងបណ្តឹងសាទុក្ខលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងខ្វះមូលដ្ឋានគតិយុត្តិដើម្បីដាក់លក្ខខណ្ឌ ចាប់បង្ខំទៅលើការដោះលែងចុងបណ្តឹងសាទុក្ខ ដូចសំអាងហេតុនានាដែលបានលើកឡើងរួចហើយ។ ជាលទ្ធផល ការដាក់លក្ខខណ្ឌណាក៏ដោយ នឹងមានលក្ខណៈវិសមាមាត្រជាក់ជាពុំខាន។

66. លើសពីនេះ ម្ចាស់បណ្តឹងសាទុក្ខខកខានពុំបានបង្ហាញថាតើការដាក់លក្ខខណ្ឌចាប់បង្ខំនៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះ មានលក្ខណៈសមស្របបែបណានោះឡើយ។ យើងពុំអាចចាត់ទុកថា វាមានលក្ខណៈសមស្របក្នុងការកំហិតព្រំដែនសិទ្ធិមនុស្សជាមូលដ្ឋានរបស់ចុងបណ្តឹងសាទុក្ខ តាមរយៈការដាក់លក្ខខណ្ឌចាប់បង្ខំបែបនេះ ក្នុងករណីដែលស្ថានភាពជាក់ស្តែងបង្ហាញយ៉ាងច្បាស់ថា ចុងបណ្តឹងសាទុក្ខនឹងពុំមានលទ្ធភាពជាសះស្បើយពីជំងឺវង្វេងវង្វាន់នេះទេនោះ។ ហេតុដូច្នេះ កិច្ចដំណើរការនីតិវិធីជំនុំជម្រះ នឹងពុំអាចចាប់ផ្តើមឡើងវិញឡើយ។ ចុងបណ្តឹងសាទុក្ខកត់សម្គាល់ឃើញថា លក្ខខណ្ឌដែលម្ចាស់បណ្តឹងសាទុក្ខបានស្នើឡើង ជាការពិត គឺមានការពាក់ព័ន្ធជាមូលដ្ឋានទៅនឹងការជំនុំជម្រះព្រហ្មទណ្ឌ ដែលនឹងអាចធ្វើឡើងនាពេលអនាគតខាងមុខ។ ដូច្នេះ លក្ខខណ្ឌទាំងនេះ ត្រូវបានកំណត់ដើម្បីធានាវត្តមានរបស់ជនជាប់ចោទនៅក្នុងពេលជំនុំជម្រះតែប៉ុណ្ណោះ[128]។ ហេតុផលថាដើម្បីការពារបុគ្គលផ្សេងតែមួយគត់ដូច្នេះ ពុំអាចជាយុត្តិកម្មសម្រាប់ការដាក់លក្ខខណ្ឌចាប់ បង្ខំចំពោះការដោះលែងឱ្យមានសេរីភាពនោះឡើយ ជាពិសេសនោះ ដោយសារម្ចាស់បណ្តឹងសាទុក្ខខ្លួនឯងនេះ ពុំបង្ហាញអំពីគ្រោះថ្នាក់ជាក់ស្តែងឱ្យយើងបានឃើញ[129] ហើយវាក៏ពុំមានភស្តុតាងបង្ហាញ

---

[127] បណ្តឹងសាទុក្ខរបស់ ក.ស.ព កថាខណ្ឌ ១៤-១៥។ សារណាបន្ថែមរបស់ ក.ស.ព កថាខណ្ឌ ១០-១៤។

[128] សូមមើលសារណាបន្ថែមរបស់ ក.ស.ព កថាខណ្ឌ ២២, ២៤, ២៥, ២៩។

[129] ដើម្បីវាយតម្លៃថាតើជនជាប់ចោទបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះ សាក្សី ឬ បុគ្គលណាម្នាក់ដែរឬអត់នោះ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានសម្រេចថា ស្ថានភាពនេះពុំអាចពិនិត្យមើល*តាមតែទ្រឹស្តី*នោះទេ៖ គ្រោះថ្នាក់ជាក់ស្តែងចាំ

ឲ្យឃើញថា ចុងបណ្ដឹងសាទុក្ខមានលទ្ធភាពធ្វើសកម្មភាពនេះដោយឯកឯងនៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្លួនផងដែរ។ ចុងបណ្ដឹងសាទុក្ខសូមរំលឹកឡើងវិញថា "វិធានការនីតិវិធីពុំគួរជាវិធានការហួសហេតុ ឬពុំមានសង្គតភាពនោះទេ"[130]។ វិធានការចាប់បង្ខំមិនគួរយកមកប្រើប្រាស់ជាវិធានការដាក់ទណ្ឌកម្មលើចុងបណ្ដឹងសាទុក្ខ ដែលជំងឺរបស់គាត់បានរារាំងពុំអាចឲ្យធ្វើការជំនុំជម្រះលើខ្លួននោះឡើយ។ ប្រសិនបើដាក់វិធានការចាប់បង្ខំមែននោះ វានឹងបង្កឲ្យមានការរំលោភលើគោលការណ៍សច្ចធារណ៍នៃនិរទោស ដូចមានចែងនៅក្នុងមាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

67. ម្យ៉ាងវិញទៀត ម្ចាស់បណ្ដឹងសាទុក្ខ ពុំបានបង្ហាញថាតើការដាក់លក្ខខណ្ឌចាប់បង្ខំទាំងនេះ មានលក្ខណៈចាំបាច់ និងលក្ខខណ្ឌសមាមាត្រយ៉ាងដូចម្ដេចនៅក្នុងកាលៈទេសៈបច្ចុប្បន្ននោះឡើយ។ ម្ចាស់បណ្ដឹងសាទុក្ខបានលើកឡើងដដែលថា គោលការណ៍សមាមាត្រទាំងមូលនៃលក្ខខណ្ឌទាំងនេះបានបង្ហាញនៅក្នុងឯកសារឧបសម្ព័ន្ធចំនួនបី ដូចបានដាក់ភ្ជាប់ទៅនឹងសារណាបន្ថែម។ នៅក្នុងឯកសារទាំងនោះ ម្ចាស់បណ្ដឹងសាទុក្ខបានធ្វើការប្រៀបធៀបរវាងរយៈពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ និងលក្ខខណ្ឌនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលត្រូវបានកំណត់នៅក្នុងករណីជាច្រើន នៅពេលមានការលើកឡើងអំពីបញ្ហាសម្បទាក្នុងការចូលរួមការជំនុំជម្រះក្ដី[131]។ ការអះអាងនេះខកខានពុំបានពិចារណាលើប្រភេទនៃសេចក្ដីសម្រេច ដែលបានផ្អែកមូលដ្ឋានលើអង្គហេតុ។

68. មាត្រា ៩ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា ចុងបណ្ដឹងសាទុក្ខមានសិទ្ធិជាមូលដ្ឋានសម្រាប់ដើរហើរ។ សិទ្ធិនេះអាចត្រូវបានកំហិតក្នុងករណីចាំបាច់ និងក្នុងករណីដែលវិធានការដែលបានធ្វើឡើងនេះ មានលក្ខណៈសមាមាត្រទៅនឹងគោលបំណងនៃការដាក់វិធានការ

---

បាច់ត្រូវតែបង្ហាញឲ្យឃើញ។ សូមមើល រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Haradinaj និងជនផ្សេងទៀត* រឿងក្ដីលេខ IT-04-84-PT សេចក្ដីសម្រេចលើញត្តិរបស់ Ramush Haradinaj ស្នើសុំការដោះលែងឲ្យមានសេរីភាពជាបណ្ដោះអាសន្ន កថាខណ្ឌ ២២ ដកស្រង់ចេញពី រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Prlic និងជនផ្សេងទៀត* រឿងក្ដីលេខ IT-04-74-AR65.1, AR65.2, AR65.3 សេចក្ដីសម្រេចលើញត្តិស្នើសុំឲ្យធ្វើការពិចារណាឡើងវិញ សុំការបញ្ជាក់បំភ្លឺ សំណើសុំដោះលែងបណ្ដោះអាសន្ន និងពាក្យសុំការអនុញ្ញាតិដាក់បណ្ដឹងសាទុក្ខ ចុះថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៤ កថាខណ្ឌ ២៨។

[130] រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Blagojevic និងជនផ្សេងទៀត* រឿងក្ដីលេខ IT-02-53-PT សេចក្ដីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទ Jokic បណ្ដោះអាសន្ន ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០២ កថាខណ្ឌ ១៨។

[131] សូមមើលសារណាបន្ថែមរបស់ ក.ស.ព កថាខណ្ឌ ១៨។

នេះប៉ុណ្ណោះ។ ដូចបានលើកឡើងពីខាងដើម ការដាក់លក្ខខណ្ឌចាប់បង្ខំចំពោះការដោះលែងឱ្យមានសេរីភាព ត្រូវធ្វើឡើងដើម្បីធានាថា ជនជាប់ចោទនឹងមានវត្តមាននៅក្នុងពេលជំនុំជម្រះតែប៉ុណ្ណោះ។ ប្រសិនបើភាគីអនុវត្តតាមលក្ខណវិនិច្ឆ័យស្តីអំពីគោលការណ៍សមាមាត្រ ដូចបានសម្រេចនៅក្នុងរឿងក្តី *Jukic* គោលដៅដែលចង់បាន គឺដើម្បីធានាវត្តមានតែប៉ុណ្ណោះ[132]។ នៅពេលដែលគេពុំរំពឹងថាការជំនុំជម្រះនឹងអាចធ្វើឡើងបាននោះ ដូចក្នុងករណីនេះជាដើម ការដាក់លក្ខខណ្ឌទាំងនេះ ពុំមានភាពចាំបាច់ និងពុំមានលក្ខណៈសមាមាត្រជាក់ជាពុំខាន។

69. ចំណុចចុងក្រោយ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងនូវការអះអាងរបស់ខ្លួន ក៏ប៉ុន្តែ ពុំបានបង្ហាញអំពី "ការបំពានឆន្ទានុសិទ្ធិ" ដោយអង្គជំនុំជម្រះសាលាដំបូងដែលខ្លួនបានចោទប្រកាន់ ហើយក៏ពុំបានបង្ហាញថា តើអង្គជំនុំជម្រះសាលាដំបូងបានបំពានឆន្ទានុសិទ្ធិនេះដោយរបៀបណានោះដែរ។ ដោយសារពុំបានបង្ហាញបែបនេះហើយ ទើបម្ចាស់បណ្តឹងសាទុក្ខខកខានពុំបានផ្តល់ទឡ្ហីករណ៍ជូនអង្គជំនុំជម្រះសាលាដំបូងសម្រាប់គាំទ្រលើមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍របស់ខ្លួន ដូចបានកំណត់នៅក្នុងវិធាន ១០៥(២) នៃវិធានផ្ទៃក្នុង។ ហេតុដូច្នេះ មូលដ្ឋានបែបនេះត្រូវតែបដិសេធចោល។

### *៤.៤ ពុំមានកំហុសអង្គហេតុដែលនាំឱ្យសេចក្តីសម្រេចមានភាពមិនយុត្តិធម៌ ឬនៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឱ្យមានការប៉ះពាល់ដល់ម្ចាស់បណ្តឹងសាទុក្ខឡើយ*

70. អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសអង្គហេតុ ឬនៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឡើយ នៅពេលសម្រេចថា លក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការនឹងមិនអាចអនុវត្តបាន ឬមិនសមហេតុផលនោះ។

#### *ក) លក្ខខណ្ឌចាប់បង្ខំដែលមិនអាចអនុវត្តបានតាមផ្លូវច្បាប់ និងតាមភាពជាក់ស្តែង*

71. អ្នកជំនាញវេជ្ជសាស្ត្របានបញ្ជាក់ថា ចុងបណ្តឹងសាទុក្ខកំពុងទទួលរង *ក្នុងចំណោមប្រការផ្សេងទៀត* នូវការធ្លាក់ចុះការចងចាំដែលត្រូវបានសម្គាល់ដោយអសមត្ថភាពទាំងស្រុងក្នុងការចងចាំ ព័ត៌មានថ្មី

---

[132] K. Khan និង R. Dixon *Archbold: បទដ្ឋានអនុវត្ត នីតិវិធី និងភស្តុតាង របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ* (Thomson Reuters និង Sweet & Maxwell, បោះពុម្ពលើកទី ៣ ឆ្នាំ ២០០៩), ទំព័រ ៣៧៣៖ "គោលបំណងចុងក្រោយនៃការឃុំខ្លួនមុនការជំនុំជម្រះ គឺដើម្បីធានាថា ជនជាប់ចោទនឹងបង្ហាញខ្លួននៅក្នុងការជំនុំជម្រះ"។

ហើយថា គាត់ស្ថិតក្នុងភាពមិនយល់ដឹងអ្វីៗនៅជុំវិញខ្លួនគាត់ឡើយ[133]។ ការធ្វើរោគវិនិច្ឆ័យនេះនាំឱ្យមានការសន្និដ្ឋានថា ចុងបណ្ដឹងសាទុក្ខនឹងមិនអាចមានការចងចាំ យល់ដឹង និងប្រតិបត្តិតាមលក្ខខណ្ឌចាប់បង្ខំណាមួយដែលបានដាក់មកលើរូបគាត់ឡើយ។ ម្ចាស់បណ្ដឹងសាទុក្ខទទួលស្គាល់យ៉ាងច្បាស់អំពីបញ្ហានេះ នៅពេលបញ្ជាក់ថា "នឹងត្រូវតែមានការលំបាកលើខ្លួនរបស់គាត់នៅក្នុងការគោរពទៅតាមលក្ខខណ្ឌទាំងអស់នេះ ដោយមិនមានការជួយពីខាងក្រៅនោះ"[134]។ ចុងបណ្ដឹងសាទុក្ខលើកឡើងថា វាផ្ទុយទៅនឹងផលប្រយោជន៍នៃភាពត្រឹមត្រូវ និងយុត្តិធម៌ក្នុងការស្នើសុំដាក់លក្ខខណ្ឌចាប់បង្ខំនៅក្នុងកាលៈទេសៈដែលមានការទទួលស្គាល់ពីភាគីនានាថា ដោយសារតែជំងឺដែលគាត់មិនអាចគ្រប់គ្រងបាននោះ គាត់មិនអាចប្រតិបត្តិតាមលក្ខខណ្ឌទាំងនោះឡើយ ហើយលក្ខខណ្ឌទាំងនោះគឺមិនសមហេតុផលឡើយ។

72. ជាដំណោះស្រាយម្យ៉ាងទៀត ម្ចាស់បណ្ដឹងសាទុក្ខបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាអំពីលទ្ធភាពតែងតាំងអាណាព្យាបាលដើម្បីធានាថា លក្ខខណ្ឌដែលដាក់ទៅលើរូបគាត់ត្រូវបានគោរព[135]។ បន្ទាប់ពីចេញសេចក្តីសម្រេចដែលរងការជំទាស់នេះ នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១២ ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលជាព្រះរាជអាជ្ញារងនៅ អ.វ.ត.ក ផងដែរនោះ បានដាក់សំណើទៅសាលាដំបូងរាជធានីភ្នំពេញសុំឱ្យមានការតែងតាំង អៀង វិជីដា ដែលជាកូនស្រីរបស់ចុងបណ្ដឹងសាទុក្ខ ជាអាណាព្យាបាលទូទៅ ដោយមានលក្ខខណ្ឌថា ចុងបណ្ដឹងសាទុក្ខត្រូវស្ថិតនៅក្នុងទឹកដីព្រះរាជាណាចក្រកម្ពុជា និងត្រូវជូនដំណឹងមកការិយាល័យរដ្ឋបាលរបស់ អ.វ.ត.ក នៅមុនពេលមានការផ្លាស់ប្ដូរអាសយដ្ឋានរបស់ចុងបណ្ដឹងសាទុក្ខ[136]។ នៅថ្ងៃទី ១៤ ខែ កញ្ញា សាលាដំបូងរាជធានីភ្នំពេញបានយល់ស្របតាមសំណើ និងបានបង្គាប់ឱ្យភ្ជាប់លក្ខខណ្ឌដែលបានបញ្ជាក់ខាងលើទៅនឹងដីកាចាត់តាំងអាណាព្យាបាល[137]។

73. នៅក្នុងសារណាបន្ថែមរបស់ខ្លួន ម្ចាស់បណ្ដឹងសាទុក្ខបញ្ជាក់ថា ពួកគាត់បានទទួលដីកាចាត់តាំងអាណាព្យាបាល បន្ទាប់ពីបានដាក់បណ្ដឹងសាទុក្ខរបស់ខ្លួន ហើយអះអាងថា សំណើសុំចាប់ផ្ដើមថៃទាំ

---

[133] របាយការណ៍សង្ខេបរបស់អ្នកជំនាញ កថាខណ្ឌ ៦០។

[134] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ១១០។

[135] ដូចយោងខាងលើ ទំព័រ ១១០-១១១។

[136] សេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ ទំព័រ ១។

[137] ដូចយោងខាងលើ ទំព័រ ៣។

ត្រូវបានដាក់ដោយ អៀង វិធីដា តាមរយៈអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ[138]។ នេះគឺជាការបញ្ជាក់មិនត្រឹមត្រូវ និងភ័ន្តច្រឡំអំពីអង្គហេតុ។ ប៉ុន្មានថ្ងៃមុនពេលចេញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ព្រះរាជអាជ្ញាបានផ្តួចផ្តើមនូវការដាក់សំណើសុំ តែងតាំងអាណាព្យាបាលទូទៅ និងបានស្នើដាក់លាក់ឲ្យ អៀង វិធីដា បំពេញនូវពាក្យសុំធ្វើជាអាណាព្យាបាលទូទៅ ដើម្បីដាក់ជូនទៅសាលាដំបូងរាជធានីភ្នំពេញ។

74. សំណើរបស់ព្រះរាជអាជ្ញាឲ្យដាក់លក្ខខណ្ឌទៅលើអាណាព្យាបាល មិនត្រូវបានជូនដំណឹងដល់ចុងបណ្តឹងសាទុក្ខ និងអាណាព្យាបាលដែលបានស្នើឡើងដែលមិនមានវត្តមាននៅពេលដែលពាក្យសុំត្រូវបានធ្វើឡើងនោះឡើយ។ នៅពេលដែលមានការចេញសេចក្តីសម្រេចនៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ ទើបព្រះរាជអាជ្ញាដាក់ពាក្យសុំឲ្យមានដីកាចាត់តាំងអាណាព្យាបាលទូទៅនៅឯសាលាដំបូងរាជធានីភ្នំពេញ។

75. ក្នុងការអនុវត្តបែបនេះ ម្ចាស់បណ្តឹងសាទុក្ខបានស្វះស្វែងស្នើសុំដើម្បីបញ្ចៀសពីយុត្តាធិការរបស់ អ.វ.ត.ក ពិសេសគឺ អង្គជំនុំជម្រះតុលាការកំពូល។ ពួកគាត់បានប្រើប្រាស់នីតិវិធីរដ្ឋប្បវេណី ដែលបង្កើតឡើងដើម្បីការពារផលប្រយោជន៍របស់បុគ្គលដែលងាយទទួលរងផលប៉ះពាល់ ជាឧបករណ៍មួយដើម្បីធានាថា ពួកគាត់ជោគជ័យនៅក្នុងការទទួលបានលក្ខខណ្ឌចាប់បង្ខំ នៅពេលដែលវាច្បាស់ណាស់ដែលថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចផ្ទុយទៅនឹងសារណារបស់ពួកគាត់នោះ។ នៅពេលដែលកំពុងរង់ចាំសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ហើយគេយល់ថាបណ្តឹងសាទុក្ខនឹងត្រូវបានដាក់ដោយចុងបណ្តឹងសាទុក្ខ ឬម្ចាស់បណ្តឹងសាទុក្ខនោះ នីតិវិធីមួយត្រូវបានចាប់ផ្តើមឡើងនៅក្នុងតុលាការមួយផ្សេងទៀត ដោយប្រើប្រាស់យុត្តាធិការរដ្ឋប្បវេណីដែលមានចេតនាដើម្បីធ្វើឲ្យលទ្ធផលនៃបណ្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល មិនមានភាពជាប់ពាក់ព័ន្ធ និងមិនមានភាពចាំបាច់។ គ្រួសាររបស់ចុងបណ្តឹងសាទុក្ខពុំបានបង្ហាញអំពីបំណងចង់ឲ្យមានការចេញដីកាចាត់តាំងអាណាព្យាបាលសម្រាប់ចុងបណ្តឹងសាទុក្ខឡើយ។ ពួកគាត់ត្រៀមខ្លួនរួចហើយដើម្បីទទួលភារកិច្ចមើលថែទាំចុងបណ្តឹងសាទុក្ខ។ នៅក្នុងកាលៈទេសៈណាក៏ដោយ ចុងបណ្តឹងសាទុក្ខអះអាងថា ក្រមរដ្ឋប្បវេណីកម្ពុជា ពុំបានចែងអំពីមូលដ្ឋានផ្លូវច្បាប់សម្រាប់ការដាក់លក្ខខណ្ឌបង្ខំទៅលើអាណាព្យាបាលដែលត្រូវបានតែងតាំងនោះឡើយ។

[138] សារណាបន្ថែមរបស់ ក.ស.ព កថាខណ្ឌ ២។

76. ចុងបណ្ដឹងសាទុក្ខអះអាងថា ម្ចាស់បណ្ដឹងសាទុក្ខមានកំហុសក្នុងការដាក់ពាក្យសុំ នៅក្នុងពាក្យពេចន៍ដែលរៀបរាប់ទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ហើយលើសពីនេះទៀតអះអាងថា តុលាការដែលបានបញ្ជាក់ជូននេះ គួរតែបដិសេធកុំដោះស្រាយទៅលើពាក្យសុំនោះ នៅពេលដែលបញ្ហានេះមិនមែនជាបញ្ហាបន្ទាន់ ហើយបញ្ហានេះគឺជាកម្មវត្ថុនៃបណ្ដឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល ដែលម្ចាស់បណ្ដឹងសាទុក្ខមិនអាចមិនទទួលស្គាល់ឡើយ ពីព្រោះពួកគាត់បានដាក់បណ្ដឹងសាទុក្ខ នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២។

77. អង្គជំនុំជម្រះសាលាដំបូងបានធ្វើការសន្និដ្ឋានយ៉ាងត្រឹមត្រូវថា លក្ខខណ្ឌបង្ខំនឹងមិនអាចអនុវត្តបានឡើយតាមផ្លូវច្បាប់ ពីព្រោះការដាក់ទណ្ឌកម្មទៅលើចុងបណ្ដឹងសាទុក្ខ ឬអាណាព្យាបាលនៅក្នុងករណីដែលមិនប្រតិបត្តិតាមនោះ គឺមិនអាចធ្វើទៅបាន ឬមិនសមហេតុផលឡើយ។

78. ការអនុវត្តនៅចំពោះមុខតុលាការអន្តរជាតិ[139] និងប្រព័ន្ធច្បាប់ជាតិ[140] រួមទាំងនៅចំពោះមុខ អ.វ.ត.ក[141] បង្ហាញថា ការខកខានរបស់ជនជាប់ចោទក្នុងការមិនប្រតិបត្តិតាមលក្ខខណ្ឌដែលបានដាក់នោះ អាចនាំឲ្យមានការបញ្ជូនមកមន្ទីរឃុំឃាំងវិញ។ ដោយពិចារណាទៅលើស្ថានភាពវេជ្ជសាស្ត្រថ្មីៗនេះរបស់ចុងបណ្ដឹងសាទុក្ខ និងការផ្អាកកិច្ចដំណើរការនីតិវិធីគ្មានកាលកំណត់ វានឹងផ្ទុយទៅនឹងច្បាប់មនុស្សធម៌ និងមិនសមហេតុផលឡើយ ក្នុងការនាំគាត់មកដាក់ក្នុងមន្ទីរឃុំឃាំងវិញនោះ។ នៅក្នុងកាលៈទេសៈណាក៏ដោយ ជនជាប់ចោទត្រូវតែគេចវេះ "ដោយចេតនា" ពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ក្នុងការសម្រេចដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន ដូចដែលបានចែងនៅក្នុងមាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ដោយពិចារណាទៅលើការចុះខ្សោយផ្នែកសតិបញ្ញារបស់គាត់ ម្ចាស់បណ្ដឹងសាទុក្ខពុំបានបង្ហាញថាតើចុង

[139] ឧទាហរណ៍ រឿងក្ដីព្រះរាជអាជ្ញា ទល់នឹង *Milan Simic* សំណុំរឿងលេខ IT-95-9-PT សេចក្ដីសម្រេចលើការដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៨ ទំព័រ ៥។ រឿងក្ដីអគ្គព្រះរាជអាជ្ញារង ទល់នឹង *Sisto Barros* ហៅ *Xisto Barros, Cesar Mendonca* និង *Josep Nahak* សំណុំរឿងលេខ 01/2004 សេចក្ដីសម្រេចលើសំណើរបស់ព្រះរាជអាជ្ញាសុំឲ្យមានការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៤ កថាខណ្ឌ ៥៥។

[140] សូមមើលមាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ សូមមើល ផងដែរ មាត្រា ១៤១-២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។

[141] វិធាន ៦៥(៦) នៃវិធានផ្ទៃក្នុង។

បណ្តឹងសាទុក្ខនឹងត្រូវបានរកឃើញថា បានបំពានទៅលើលក្ខខណ្ឌដែលបានដាក់មកលើរូបគាត់នោះ តាមវិធីណាឡើយ។

79. លើសពីនេះទៀត អាណាព្យាបាលដែលតែងតាំងដោយតុលាការ មិនអាចទទួលខុសត្រូវចំពោះការខកខានរបស់បុគ្គល ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ខ្លួនក្នុងការមិនប្រតិបត្តិតាមលក្ខខណ្ឌបង្ខំនៃការត្រួតពិនិត្យតាមផ្លូវតុលាការនោះឡើយ។ យោងតាមច្បាប់កម្ពុជា តួនាទីរបស់គាត់ គឺការពារទ្រព្យសម្បត្តិរបស់បុគ្គល ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ខ្លួន[142] និងផ្តល់ការថែទាំវេជ្ជសាស្ត្រ និងផ្តល់នូវការជួយទូទៅដល់បុគ្គលនោះ[143]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់យ៉ាងត្រឹមត្រូវ ការតែងតាំងអាណាព្យាបាលមិនមែនមានគោលបំណងដើម្បីធានាឲ្យមានការគោរពតាមលក្ខខណ្ឌដែលបានដាក់ទៅលើជនជាប់ចោទ នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ[144]។ ដូច្នេះ លទ្ធភាពក្នុងការដាក់ទណ្ឌកម្មទៅលើអាណាព្យាបាលរបស់ចុងបណ្តឹងសាទុក្ខ ចំពោះការមិនគោរពតាមលក្ខខណ្ឌ ដែលបានដាក់មកលើចុងបណ្តឹងសាទុក្ខនោះ គឺពុំមានមូលដ្ឋានផ្លូវច្បាប់ឡើយ។

80. ម្ចាស់បណ្តឹងសាទុក្ខលើកឡើងទៀតថា សំអាងហេតុដែលថាលក្ខខណ្ឌបង្ខំមិនអាចអនុវត្តបានតាមភាពជាក់ស្តែង និងតាមផ្លូវច្បាប់ គឺផ្ទុយគ្នាទៅនឹង “ការស្នើ” និង “ការរំឭក” របស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់[145]។ តាមរយៈការរំឭកដល់ម្ចាស់បណ្តឹងសាទុក្ខអំពីកាតព្វកិច្ចពីមុនក្នុងការមិនជ្រៀតចូលទៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ អង្គជំនុំជម្រះសាលាដំបូងពុំបានបង្កើតនូវលក្ខខណ្ឌចាប់បង្ខំថ្មី ដែលអាចយកមកអនុវត្តបានតែចំពោះចុងបណ្តឹងសាទុក្ខឡើយ ក្រៅតែពីស្នើមិនឲ្យរូបគាត់ប្រាស្រ័យទាក់ទងជាមួយប្រព័ន្ធសារព័ត៌មាន។

81. អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា វាជាការមិនសមហេតុផល និងខុសច្បាប់ក្នុងការដាក់លក្ខខណ្ឌចាប់បង្ខំថ្មីទៅលើចុងបណ្តឹងសាទុក្ខ ដោយពិចារណាទៅលើការចុះខ្សោយផ្នែកសតិបញ្ញារបស់គាត់។

---

142 មាត្រា ១០២៨(១) នៃក្រមរដ្ឋប្បវេណីកម្ពុជា។

143 ដូចយោងខាងលើ មាត្រា ១០៣៩(១)។

144 សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣៧ ជើងទំព័រ ៨៦។

145 បណ្តឹងសាទុក្ខរបស់ ក.ស.ព កថាខណ្ឌ ១៧។

*ខ) ការវាយតម្លៃជាទៀងទាត់អំពីសុខភាពខាងផ្លូវចិត្តរបស់ចុងបណ្តឹងសាទុក្ខ គឺគ្មានយុត្តិកម្មឡើយ*

82. ម្ចាស់បណ្តឹងសាទុក្ខលើកឡើងថា អង្គជំនុំជម្រះមានកំហុសនៅក្នុងការអនុវត្តសេចក្តីបង្គាប់របស់ខ្លួន និងបានធ្វើឲ្យមានភាពមិនយុត្តិធម៌ ដែលបណ្តាលឲ្យប៉ះពាល់ដល់ម្ចាស់បណ្តឹងសាទុក្ខ នៅក្នុងការយល់ឃើញថា "ការលំបាក និងការចំណាយជាក់ស្តែងក្នុងការបន្តធ្វើការវាយតម្លៃឡើងវិញតាមពេលវេលាកំណត់លើសម្បទាបញ្ញាស្មារតីរបស់ជនជាប់ចោទ រួមទាំងការសម្រេចថា ស្ថានភាពរបស់ជនជាប់ចោទមិនអាចព្យាបាលឲ្យជាបាន និងមិនអាចស្តារឡើងវិញបាន មិនផ្តល់យុត្តិកម្មដល់ការវាយតម្លៃវេជ្ជសាស្ត្រជាធម្មតាលើជនជាប់ចោទឡើយ"[146]។

83. ចុងបណ្តឹងសាទុក្ខអះអាងថា ម្ចាស់បណ្តឹងសាទុក្ខពុំបានបង្ហាញថាតើការរំលោភឆន្ទានុសិទ្ធិដែលបានចោទប្រកាន់នោះបណ្តាលឲ្យប៉ះពាល់ដល់ពួកគាត់បែបណានោះឡើយ។ ដោយខកខានពុំបានធ្វើការបង្ហាញបែបនេះ ម្ចាស់បណ្តឹងសាទុក្ខពុំបានលើកយកភស្តុតាងមកបញ្ជាក់ឡើយ ដូច្នេះ មូលដ្ឋាននៃបណ្តឹងសាទុក្ខត្រូវតែបដិសេធចោល។

84. វាច្បាស់ណាស់ដែលថា ចុងបណ្តឹងសាទុក្ខកំពុងទទួលរងនូវជំងឺដែលចុះដុនដាបវិវឌ្ឍន៍ទៅមុខ ហើយថា ស្ថានភាពរបស់គាត់នៅពេលនេះមិនអាចព្យាបាលបានឡើយ។ ការពុំមានការព្យាបាលណាមួយដែលអាចធ្វើឲ្យសមត្ថភាពផ្នែកបញ្ញាស្មារតីរបស់គាត់ល្អប្រសើរឡើងវិញបាននោះ ការបង្គាប់ឲ្យមានការវាយតម្លៃតាមកាលកំណត់ទៀតទាត់ទៅលើសម្បទាបញ្ញាស្មារតីរបស់គាត់ ពុំមានមូលដ្ឋានអង្គហេតុ និងអង្គច្បាប់ឡើយ។ ដោយទទួលស្គាល់នូវសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញវេជ្ជសាស្ត្រ សេចក្តីសម្រេចដែលរងការជំទាស់មានមូលដ្ឋានសំអាងគ្រប់គ្រាន់ និងមិនធ្វើឲ្យមានភាពមិនយុត្តិធម៌នោះឡើយ។

85. លើសពីនេះទៀត ចុងបណ្តឹងសាទុក្ខអះអាងថា ការដាក់ឲ្យមានការវាយតម្លៃវេជ្ជសាស្ត្រសម្រាប់ផលប្រយោជន៍របស់ចុងបណ្តឹងសាទុក្ខ មិនស្ថិតនៅក្នុងវិសាលភាពនៃវិធានផ្ទៃក្នុងជាធរមានដែលបានបញ្ជាក់ជូនខាងលើឡើយ ដូច្នេះការវាយតម្លៃវេជ្ជសាស្ត្រមិនមែនសំដៅធានានូវវត្តមានរបស់ជនជាប់ចោទក្នុងអំឡុងកិច្ចដំណើរការនីតិវិធីឡើយ ហើយក៏មិនសំដៅការពារអ្នកដទៃទៀតនោះដែរ។

86. ជាលទ្ធផល សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនបង្គាប់ឲ្យចុងបណ្តឹងសាទុក្ខស្ថិតនៅក្រោមការត្រួតពិនិត្យវេជ្ជសាស្ត្រជាទៀងទាត់ពីសំណាក់វេជ្ជបណ្ឌិត ដែលតែងតាំងដោយតុលាការ

---

[146] បណ្តឹងសាទុក្ខរបស់ ក.ស.ព កថាខណ្ឌ ១៨។

មានមូលដ្ឋានសំអាងគ្រប់គ្រាន់ និងមិនធ្វើឲ្យមានភាពមិនយុត្តិធម៌នោះទេ ហើយក៏មិនបានបង្ហាញឲ្យឃើញនូវកំហុសនៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

## V សំណើសុំឲ្យមានសវនាការដោយផ្ទាល់មាត់

87. មានការអះអាងថា បញ្ហាដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខ មានសារៈសំខាន់យ៉ាងខ្លាំង ហើយគួរតែត្រូវបានដោះស្រាយឲ្យបានសមរម្យ និងត្រឹមត្រូវបំផុតក្នុងអំឡុងសវនាការដោយផ្ទាល់មាត់ ដែលនឹងផ្តល់ឲ្យភាគីនានានូវឱកាសដើម្បីឆ្លើយតបឲ្យបានលម្អិតថែមទៀតទៅនឹងអង្គហេតុដូចដែលបានលើកឡើងនៅក្នុងពាក្យសុំនេះ និងច្បាប់ជាធរមាន។ ដូច្នេះ ចុងបណ្តឹងសាទុក្ខស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលកំណត់ពេលវេលាសវនាការសម្រាប់បញ្ហានេះ។

## VI សេចក្តីសន្និដ្ឋាន

88. ដោយសេចក្តីគោរព ចុងបណ្តឹងសាទុក្ខសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង៖

ក. អនុញ្ញាតឲ្យមានសវនាការដោយផ្ទាល់មាត់លើបណ្តឹងសាទុក្ខនេះ។

ខ. បដិសេធបណ្តឹងសាទុក្ខចោលទាំងស្រុង និងតម្កល់សេចក្តីសម្រេចដែលរងការជំទាស់របស់អង្គជំនុំជម្រះសាលាដំបូង។

គ. ដកចេញនូវលក្ខខណ្ឌបង្ខំដែលបានដាក់ភ្ជាប់ទៅនឹងការដោះលែង អៀង ធីរិទ្ធ នាពេលថ្មីៗនេះ។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះមេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់ អៀង ធីរិទ្ធ | ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | Diana Ellis |